# ព្រះរាជក្រម

នស/រកម/១១២០/ ០២៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅះ



Media from www.moj.gov.kh resource from www.ocm.gov.kh

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត

**មាត្រា១.-**

អនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នៅទីក្រុងគូម៉ាម៉ូតូនៃប្រទេសជប៉ុន នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ និងបានចូលជាធរមាន នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ។

ថ្ងៃ សៅរ៍ ១៤ រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០

[illegible]

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**



Media from www.moj.gov.kh resource from www.ocm.gov.kh

# សេចក្តីផ្តើម

ក្នុងឆ្នាំ២០០១ ក្រុមប្រឹក្សាភិបាលនៃកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) បានអញ្ជើញនាយកប្រតិបត្តិអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិឱ្យធ្វើការសិក្សាវាយតម្លៃជាសកលអំពីបារតនិងសមាសធាតុបារត រួមមាន ព័ត៌មានអំពីគីមីសាស្ត្រនិងផលប៉ះពាល់សុខភាព ប្រភព ការផ្លាស់ទីរយៈចម្ងាយឆ្ងាយ បច្ចេកវិទ្យាការពារនិងគ្រប់គ្រងដែលទាក់ទងទៅនឹងបារត។ នៅក្នុងឆ្នាំ២០០៣ ក្រុមប្រឹក្សាភិបាលបានពិចារណាលើការសិក្សាវាយតម្លៃបារត និងបានរកឃើញភស្តុតាងគ្រប់គ្រាន់អំពីផលប៉ះពាល់ធ្ងន់ធ្ងរជាសកល ដែលបង្កឡើងពីបារតនិងសមាសធាតុបារត ដោយទាមទារឱ្យមាននូវវិធានការអន្តរជាតិបន្ថែមទៀតសំដៅកាត់បន្ថយផលប៉ះពាល់លើសុខភាពមនុស្សនិងបរិស្ថាន ដែលបណ្តាលមកពីការសាយភាយបារតនិងសមាសធាតុបារតចូលទៅក្នុងបរិស្ថាន។ រដ្ឋាភិបាលនៃបណ្តាប្រទេស ត្រូវបានជំរុញឱ្យអនុម័តគោលដៅសម្រាប់កាត់បន្ថយការបញ្ចេញនិងការសាយភាយបារត ហើយកម្មវិធីបរិស្ថានសហប្រជាជាតិបានផ្តួចផ្តើមគំនិតលើការផ្តល់ជំនួយបច្ចេកទេសនិងសកម្មភាពកសាងសមត្ថភាព ដើម្បីសម្រេចបានគោលដៅទាំងនេះ។

បារតត្រូវបានទទួលស្គាល់ជាសារធាតុដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធប្រសាទ និងផលប៉ះពាល់ផ្សេងៗទៀតដល់សុខភាព ដែលធ្វើឱ្យមានការព្រួយបារម្ភជាពិសេសអំពីផលប៉ះពាល់ធ្ងន់ធ្ងរទៅលើទារកនិងគភ៌ក្នុងផ្ទៃពោះ។ ការសាយភាយជាសកលនៃបារតនៅក្នុងបរិស្ថាន គឺជាហេតុផលមួយដ៏សំខាន់សម្រាប់ ការធ្វើសេចក្តីសម្រេចក្នុងការចាត់វិធានការជាសកល ដើម្បីឆ្លើយតបទៅនឹងបញ្ហាពាក់ព័ន្ធការបំពុលដោយបារត។ កម្មវិធីបារតដើម្បីឆ្លើយតបទៅនឹងកង្វល់ទាំងនេះ ត្រូវបានបង្កើតឡើងនិងបានពង្រឹងបន្ថែមដោយរដ្ឋាភិបាលនៃបណ្តាប្រទេសនៅក្នុងសេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាលនៅក្នុងឆ្នាំ២០០៥ និងឆ្នាំ២០០៧។ នៅក្នុងសេចក្តីសម្រេចឆ្នាំ២០០៧ ក្រុមប្រឹក្សាភិបាលបានសម្រេចថារាល់ជម្រើសនៃវិធានការធ្វើឱ្យប្រសើរឡើងដោយស្ម័គ្រចិត្ត និងលិខិតូបករណ៍អន្តរជាតិថ្មីឬមានស្រាប់ នឹងត្រូវពិនិត្យនិងវាយតម្លៃឡើងវិញដើម្បីធ្វើឱ្យមានវឌ្ឍនភាពក្នុងការឆ្លើយតបទៅនឹងបញ្ហាពាក់ព័ន្ធបារត។

នៅឆ្នាំ២០០៩ បន្ទាប់ពីមានការគិតគូរពិចារណាគ្រប់ជ្រុងជ្រោយលើបញ្ហានេះ ក្រុមប្រឹក្សាភិបាលបានឯកភាពថា វិធានការដែលស្ម័គ្រចិត្តមិនទាន់គ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងការព្រួយបារម្ភពីបារតនោះទេ ហើយបានសម្រេចឱ្យមានវិធានការបន្ថែមទៀតសម្រាប់ឆ្លើយតបទៅនឹងបញ្ហាបារត រួមមានការរៀបចំលិខិតូបករណ៍ដែលមានកាតព្វកិច្ចផ្លូវច្បាប់ជាសកល។ គណៈកម្មាធិការចរចាអន្តររដ្ឋាភិបាល ត្រូវបានបង្កើតឡើង ដើម្បីរៀបចំលិខិតូបករណ៍ដែលមានកាតព្វកិច្ចផ្លូវច្បាប់ជាសកល ហើយបានចាប់ផ្តើមដំណើរការងារនៅឆ្នាំ២០១០និងបានបញ្ចប់កិច្ចចរចាមុនពេលកិច្ចប្រជុំលើកទី២៧នៃក្រុមប្រឹក្សាភិបាលនៅក្នុងឆ្នាំ២០១៣។ គណៈកម្មាធិការមានតួនាទីភារកិច្ចកំណត់នូវបញ្ហាជាក់លាក់ ដែលត្រូវបញ្ចូលនៅក្នុងខ្លឹមសារលិខិតូបករណ៍ ព្រមទាំងធាតុចូលផ្សេងៗដែលត្រូវយកមកពិចារណានៅក្នុងពេលចរចា។

នៅក្នុងខែមករា ឆ្នាំ២០១៣ គណៈកម្មាធិការចរចាអន្តររដ្ឋាភិបាល បានបញ្ចប់នូវកិច្ចប្រជុំលើកទី៥ ដោយបានឯកភាពលើខ្លឹមសារនៃអនុសញ្ញាមីណាម៉ាតាស្តីពីបារត។ ខ្លឹមសារអនុសញ្ញាមីណាម៉ាតា ត្រូវបានអនុម័តដោយសន្និសីទអន្តររដ្ឋាភិបាលនាថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ក្នុងប្រទេសជប៉ុន ហើយបានដាក់ឱ្យចុះហត្ថលេខាបន្ទាប់ពីពេលនោះមក ។ កម្មវត្ថុនៃអនុសញ្ញានេះ គឺដើម្បីការពារសុខភាពមនុស្សនិងបរិស្ថាន

ពីការបញ្ចេញនិងការសាយភាយបារតនិងសមាសធាតុបារតដោយសកម្មភាពមនុស្ស ហើយដាក់ចេញនូវវិធានការមួយចំនួនដើម្បីសម្រេចបាននូវកម្មវត្ថុនេះ។ វិធានការទាំងនោះ រួមមានការគ្រប់គ្រង ការផ្គត់ផ្គង់ និងការធ្វើពាណិជ្ជកម្មបារត ព្រមទាំងការកំណត់កម្រិតលើប្រភពសាយភាយបារតជាក់លាក់ដូចជា ការធ្វើអាជីវកម្មរ៉ែចម្បង និងការគ្រប់គ្រងត្រួតពិនិត្យផលិតផលមានបន្ថែមបារតនិងច្រវ៉ាក់ផលិតកម្មដែលមានប្រើប្រាស់បារតឬសមាសធាតុបារត ព្រមទាំងអាជីវកម្មរ៉ែមាសខ្នាតតូចផងដែរ។ ខ្លឹមសារនៃអនុសញ្ញាមីណាម៉ាតា មានបញ្ចូលមាត្រាដាច់ដោយឡែកស្តីពីការបញ្ចេញនិងការសាយភាយបារត ដោយមានការត្រួតពិនិត្យលើកម្រិតកាត់បន្ថយបារត ដែលអនុញ្ញាតឱ្យមានភាពបត់បែនក្នុងការរៀបចំផែនការអភិវឌ្ឍន៍ជាតិ។ បន្ថែមពីនេះទៅទៀត អនុសញ្ញានេះមានបញ្ចូលនូវវិធានការស្តីពីការស្តុកទុកបារតនិងសំណល់បារតបណ្តោះអាសន្នប្រកបដោយសុវត្ថិភាពបរិស្ថាន ព្រមទាំងទីតាំងដែលទទួលរងការបំពុលផងដែរ។ អនុសញ្ញានេះ ក៏មានបញ្ញត្តិស្តីពីការផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍនិងប្រទេសស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល ហើយក៏បានកំណត់យន្តការសម្រាប់ការផ្តល់ធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាតាមការកំណត់។

រដ្ឋាភិបាលនៃបណ្តាប្រទេស ត្រូវបានអញ្ជើញចូលរួមនិងលើកទឹកចិត្តដល់ការចុះហត្ថលេខាលើអនុសញ្ញានេះនៅការិយាល័យតម្កល់ឯកសារ ទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កនៅអំឡុងពេលដាក់ឱ្យចុះហត្ថលេខា (រហូតដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤)។ រដ្ឋាភិបាលនៃបណ្តាប្រទេស ក៏ត្រូវបានលើកទឹកចិត្តដល់ការអនុវត្តអនុសញ្ញានេះនិងផ្តល់សច្ចាប័នក្លាយជាភាគី ដើម្បីឈានទៅដល់ការចូលជាធរមាននៃអនុសញ្ញានេះឱ្យបានកាន់តែឆាប់រហ័ស។

អនុសញ្ញានេះត្រូវបានរំពឹងថា ការអនុវត្តកាតព្វកិច្ចនៃអនុសញ្ញានេះដោយមានការសម្របសម្រួលនឹងឆ្ពោះទៅរកការកាត់បន្ថយជារួមនៃកម្រិតបារតចូលក្នុងបរិស្ថានកន្លងមក ដែលនឹងសម្រេចបាននូវកម្មវត្ថុនៃអនុសញ្ញានេះដើម្បីការពារសុខភាពមនុស្សនិងបរិស្ថាន ពីការបញ្ចេញនិងការសាយភាយបារតនិងសមាសធាតុបារតដោយសកម្មភាពមនុស្ស។

# អនុសញ្ញាមីណាម៉ាតា
# ស្ដីពីបារត

ភាគីនៃអនុសញ្ញានេះ

- ទទួលស្គាល់ថា បារតគឺជាសារធាតុគីមីគ្រោះថ្នាក់មួយដែលសកលលោកមានការបារម្ភយ៉ាងខ្លាំង ដោយសារការផ្លាស់ទីឆ្ងាយនៅក្នុងបរិយាកាស ភាពមិនងាយបំបែកជាតុនៅក្នុងបរិស្ថាននៅពេលដែលត្រូវបាន បង្កឡើងពីសកម្មភាពរបស់មនុស្ស លទ្ធភាពបង្កើនបរិមាណសារធាតុបារតនៅក្នុងសារពាង្គកាយនៃជីវិតនៅក្នុង ប្រព័ន្ធអេកូឡូស៊ី និងផលប៉ះពាល់ធ្ងន់ធ្ងររបស់បារតទៅលើសុខភាពមនុស្សនិងបរិស្ថាន។

- ចងចាំនូវសេចក្ដីសម្រេចលេខ២៥/៥ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រុមប្រឹក្សាភិបាលនៃ កម្មវិធីបរិស្ថានសហប្រជាជាតិ បានផ្ដួចផ្ដើមសកម្មភាពជាអន្តរជាតិដើម្បីគ្រប់គ្រងបារតប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងមានលក្ខណៈប្រទាក់ក្រឡាគ្នា។

- ចងចាំនូវវាក្យខណ្ឌ២២១ នៃឯកសារលទ្ធផលរបស់សន្និសីទសហប្រជាជាតិស្ដីពីការអភិវឌ្ឍប្រកប ដោយចីរភាព « អនាគតដែលយើងចង់បាន » ដែលបានអំពាវនាវឱ្យសម្រេចលទ្ធផលប្រកបដោយជោគជ័យ នៃកិច្ចចរចាលើលិខិតូបករណ៍ជាសកលស្ដីពីបារត ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន។

- ចងចាំនូវការអះអាងជាថ្មីអំពីគោលការណ៍នៃសេចក្ដីថ្លែងការណ៍ទីក្រុងរីយ៉ូស្ដីពីបរិស្ថាន និងការ អភិវឌ្ឍនៃអង្គសន្និសីទសហប្រជាជាតិស្ដីពីការអភិវឌ្ឍប្រកបដោយចីរភាព ដែលរួមមានគោលការណ៍ ការទទួលខុសត្រូវរួមគ្នាប៉ុន្តែមានតួនាទីផ្សេងគ្នា និងការទទួលស្គាល់ស្ថានភាពនិងសមត្ថភាពផ្សេងគ្នារបស់ ប្រទេសជាសមាជិក ព្រមទាំងតម្រូវការសកម្មភាពជាសកល។

- យល់ដឹងអំពីក្ដីបារម្ភពីសុខភាព ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដែលបង្កឡើងដោយ ផលប៉ះពាល់ពីបារតលើជនងាយរងគ្រោះ ជាពិសេសស្ត្រី កុមារ និងមនុស្សជំនាន់ក្រោយទៀត។

- កត់សម្គាល់ថា ភាពងាយទទួលរងគ្រោះជាពិសេសនៃស្ថានប្រព័ន្ធតំបន់អាកទិកនិងសហគមន៍ ជនជាតិដើមនៅតំបន់នោះ ដោយសារកំណើនបរិមាណបារតពីភាវរស់មួយទៅភាវរស់មួយ និងការបំពុល ចំណីអាហារប្រពៃណី និងក្ដីបារម្ភជាទូទៅអំពីផលប៉ះពាល់បង្កឡើងដោយបារតលើសហគមន៍ជនជាតិដើម។

- ទទួលស្គាល់បទពិសោធដ៏សំខាន់នៃជំងឺមីណាម៉ាតា ជាពិសេសផលប៉ះពាល់ធ្ងន់ធ្ងរលើសុខភាព និងបរិស្ថានដែលបង្កដោយការបំពុលបារត និងតម្រូវការដើម្បីធានាការគ្រប់គ្រងបារតប្រកបដោយភាព ត្រឹមត្រូវនិងការទប់ស្កាត់នូវមហន្តរាយបែបនេះកើតឡើងនាថ្ងៃអនាគត។

- គូសបញ្ជាក់ពីសារៈសំខាន់នៃការគាំទ្រលើផ្នែកហិរញ្ញវត្ថុ បច្ចេកទេស បច្ចេកវិទ្យា និងការបង្កើន សមត្ថភាព ជាពិសេសសម្រាប់បណ្ដាប្រទេសកំពុងអភិវឌ្ឍនិងប្រទេសស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាលដើម្បី ពង្រឹងសមត្ថភាពថ្នាក់ជាតិក្នុងការគ្រប់គ្រងបារតនិងលើកកម្ពស់ការអនុវត្តអនុសញ្ញាប្រកបដោយប្រសិទ្ធភាព។

- ទទួលស្គាល់ផងដែរថា សកម្មភាពរបស់អង្គការសុខភាពពិភពលោកក្នុងការការពារសុខភាពមនុស្ស ដែលទាក់ទងទៅនឹងបារតនិងតួនាទីនៃកិច្ចព្រមព្រៀងពហុភាគីពាក់ព័ន្ធវិស័យបរិស្ថាន ជាពិសេសអនុសញ្ញា បាសែលស្ដីពីការត្រួតពិនិត្យចលនាដឹកជញ្ជូននិងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន អនុសញ្ញា

ស្តុកខូមស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ និងអនុសញ្ញារ៉ូថឺដាមស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ។

- ទទួលស្គាល់ថា អនុសញ្ញានេះនិងកិច្ចព្រមព្រៀងអន្តរជាតិពហុភាគីពាក់ព័ន្ធវិស័យបរិស្ថាន និងពាណិជ្ជកម្មដទៃទៀតគឺជួយគាំទ្រគ្នាទៅវិញទៅមក។

- គូសបញ្ជាក់ថា ពុំមានបញ្ញត្តិទាំងឡាយណានៅក្នុងអនុសញ្ញានេះធ្វើឱ្យប៉ះពាល់ទៅលើសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីណាមួយនៃអនុសញ្ញាអន្តរជាតិដែលនៅជាធរមាន។

- យល់ឃើញថា សេចក្តីរៀបរាប់ខាងលើគឺមិនមានបំណងដើម្បីបង្កើតឋានានុក្រមរវាងអនុសញ្ញានេះនិងលិខិតូបករណ៍អន្តរជាតិផ្សេងទៀតទេ។

- កត់សម្គាល់ថា ពុំមានបញ្ញត្តិទាំងឡាយណានៅក្នុងអនុសញ្ញានេះរារាំងដល់ភាគីក្នុងការចាត់នូវវិធានការថ្នាក់ជាតិបន្ថែមដោយអនុលោមតាមបញ្ញត្តិនានានៃអនុសញ្ញានេះ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារសុខភាពមនុស្សនិងបរិស្ថានពីការទទួលរងឥទ្ធិពលពីបារត ផ្អែកតាមកាតព្វកិច្ចផ្សេងៗទៀតរបស់ភាគីនៅក្រោមច្បាប់អន្តរជាតិដែលនៅជាធរមាន។

បានយល់ព្រមគ្នាដូចតទៅៈ

## មាត្រា១
## កម្មវត្ថុ

កម្មវត្ថុនៃអនុសញ្ញានេះ គឺដើម្បីការពារសុខភាពមនុស្សនិងបរិស្ថាន ពីការបញ្ចេញនិងការសាយភាយបារតនិងសមាសធាតុបារតពីសកម្មភាពរបស់មនុស្ស។

## មាត្រា២
## និយមន័យ

សម្រាប់គោលបំណងនៃអនុសញ្ញានេះៈ

**(ក) « អាជីវកម្មរ៉ែមាសខ្នាតតូច »** សំដៅដល់អាជីវកម្មរ៉ែមាសដែលដំណើរការដោយកម្លាំងផ្ទាល់ខ្លួន ឬសិប្បកម្មខ្នាតតូចដែលមានទុនវិនិយោគនិងផលិតកម្មមានកម្រិត។

**(ខ) « បច្ចេកទេសដ៏ប្រសើរដែលអាចរកបាន »** សំដៅដល់បច្ចេកទេសទាំងឡាយដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការទប់ស្កាត់និងក្នុងការកាត់បន្ថយការបញ្ចេញនិងការសាយភាយបារត (នៅទីកន្លែងដែលពុំអាចទប់ស្កាត់បាន) ទៅក្នុងខ្យល់ ទឹក និងដី ព្រមទាំងផលប៉ះពាល់នៃការបញ្ចេញនិងការសាយភាយនេះចូលក្នុងបរិស្ថាន ដោយត្រូវគិតគូរលើកត្តាសេដ្ឋកិច្ចនិងបច្ចេកទេសរបស់ភាគីទទួល និងបរិក្ខារដែលផ្តល់ឱ្យក្នុងដែនដីនៃភាគីទទួលនោះ។ នៅក្នុងបរិបទនេះៈ

(១) **« ដ៏ប្រសើរ »** សំដៅដល់ប្រសិទ្ធភាពខ្ពស់ក្នុងការសម្រេចបាននូវកម្រិតខ្ពស់ជាទូទៅនៃការការពារបរិស្ថាន

(២) បច្ចេកទេស **« ដែលអាចរកបាន »** ចំពោះភាគីទទួលនិងបរិក្ខារដែលផ្តល់ឱ្យនៅក្នុងដែនដីនៃភាគីទទួលនោះ សំដៅដល់បច្ចេកទេសទាំងឡាយដែលត្រូវបានបង្កើតក្នុងកម្រិតដែលអនុញ្ញាតឱ្យអនុវត្តនៅក្នុងវិស័យឧស្សាហកម្ម សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច



Media from www.moj.gov.kh resource from www.ocm.gov.kh

និងបច្ចេកទេសដែលបានគិតគូរលើទំហំចំណាយនិងផលចំណេញពីបច្ចេកទេសទាំងនោះ ដែលត្រូវបានប្រើប្រាស់ឬបង្កើតនៅក្នុងដែនដីនៃភាគីទទួលឬដែលបច្ចេកទេសទាំងនេះអាចត្រូវបានប្រើប្រាស់ដោយអ្នកបញ្ជានូវបរិក្ខារទាំងនោះ ដែលកំណត់ដោយភាគីទទួល និង

(៣) « **បច្ចេកទេស** » សំដៅដល់បច្ចេកវិទ្យាប្រើប្រាស់ របៀបនៃការប្រតិបត្តិ និងវិធីសាស្ត្រដែលបរិក្ខារត្រូវបានរចនា ដំឡើង ថែទាំ ដំណើរការ និងបញ្ចប់ដំណើរការ។

(គ) « **កិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ** » សំដៅដល់ការអនុវត្តវិធានការនិងយុទ្ធសាស្ត្រត្រួតពិនិត្យបរិស្ថានដោយសមស្រប។

(ឃ) « **បារត** » សំដៅដល់អង្គធាតុបារត (Hg(0), CAS No. 7439-97-6)

(ង) « **សមាសធាតុបារត** » សំដៅដល់សារធាតុទាំងឡាយណាដែលមានផ្ទុកអាតូមបារតនិងអាតូមមួយឬច្រើននៃធាតុគីមីផ្សេងទៀត ហើយដែលអាចត្រូវបានផ្តាច់ចេញពីគ្នាទៅជាសមាសភាគផ្សេងទៀតតាមរយៈប្រតិកម្មគីមីប៉ុណ្ណោះ

(ច) « **ផលិតផលមានបន្ថែមបារត** » សំដៅដល់ផលិតផលមួយឬសមាសភាគផលិតផលមានផ្ទុកបារតឬសមាសធាតុបារតដែលត្រូវបានដាក់បន្ថែមដោយចេតនា

(ឆ) « **ភាគី** » សំដៅដល់រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលបានយល់ព្រមទទួលអនុវត្តនូវអនុសញ្ញានេះ នៅពេលដែលអនុសញ្ញានេះកំពុងនៅជាធរមាន

(ជ) « **វត្តមានរបស់ភាគីនិងការបោះឆ្នោត** » សំដៅដល់វត្តមានរបស់ភាគីជាសមាជិកនិងការបោះឆ្នោតរបស់ភាគី ជាវិជ្ជមានឬអវិជ្ជមាន

(ឈ) « **ការធ្វើអាជីវកម្មរ៉ែបារតចម្បង** » សំដៅដល់ការធ្វើអាជីវកម្មរ៉ែក្នុងការស្វែងរកបារតជាចម្បង

(ញ) « **អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់** » សំដៅដល់អង្គការដែលត្រូវបង្កើតឡើងដោយរដ្ឋអធិបតេយ្យក្នុងតំបន់ ហើយរដ្ឋជាសមាជិកនៃអង្គការនោះបានផ្ទេរសមត្ថកិច្ចនិងសិទ្ធិអំណាចទៅឱ្យអង្គការនោះ និងត្រូវទទួលសិទ្ធិយ៉ាងពេញលេញដើម្បីចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលយល់ព្រម ឬសុំចូលជាសមាជិករបស់អនុសញ្ញានេះ ដោយអនុលោមទៅតាមគោលការណ៍ផ្ទៃក្នុងរបស់អង្គការនេះ

(ដ) « **ការប្រើប្រាស់ដែលអនុញ្ញាត** » សំដៅដល់ការប្រើប្រាស់ណាមួយដោយភាគីនូវបារតឬសមាសធាតុបារត ស្របតាមអនុសញ្ញានេះ រួមមានដោយមិនកំណត់ត្រឹមតែលើការប្រើប្រាស់បារតឬសមាសធាតុបារតស្របតាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ និងមាត្រា៧។

## មាត្រា៣
## ប្រភពផ្គត់ផ្គង់និងការធ្វើពាណិជ្ជកម្មបារត

១- សម្រាប់គោលបំណងនៃមាត្រានេះ៖

(ក) យោង « បារត » រាប់បញ្ចូលទាំងការលាយបញ្ចូលបារតជាមួយសមាសធាតុផ្សេងទៀត រួមមានសំលោហៈផ្សំពីបារត ដែលមានកំហាប់បារតយ៉ាងហោចណាស់ ៩៥% ធៀបនឹងទម្ងន់ និង

(ខ) « សមាសធាតុបារត » សំដៅដល់បារត(I)ក្លរីត (ដែលស្គាល់ថាជា calomel) បារត(II)អុកស៊ីត បារត(II)ស៊ុលផាត បារត(II)នីត្រាត ស៊ីនណាបា(cinnabar) និងបារតស៊ុលភីត

២- បទប្បញ្ញត្តិនៃមាត្រានេះ មិនមានវិសាលភាពអនុវត្តចំពោះ៖

(ក) បរិមាណបារតឬសមាសធាតុបារតដែលត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវនៅមន្ទីរពិសោធន៍ ឬស្តង់ដាយោង ឬ

(ខ) បរិមាណតិចតួចនៃបារតឬសមាសធាតុបារតដែលកើតមានឡើងតាមធម្មជាតិ មានវត្តមានក្នុងផលិតផលដូចជា លោហៈធាតុមិនមែនបារត រ៉ែធម្មជាតិឬផលិតផលរ៉ែខនិជ រួមមានធ្យូងថ្មឬផលិតផលដែលបម្លែងចេញពីវត្ថុធាតុទាំងនោះ និងបរិមាណតិចតួចដែលមានដោយអចេតនាក្នុងផលិតផលគីមី ឬ

(គ) ផលិតផលមានបន្ថែមបារត។

៣- ភាគីនីមួយៗមិនអនុញ្ញាតឱ្យធ្វើអាជីវកម្មរ៉ែបារតចម្បងដែលមិនស្ថិតនៅក្នុងដែនដីរបស់ខ្លួន នៅពេលអនុសញ្ញានេះចូលជាធរមាន។

៤- ភាគីនីមួយៗអនុញ្ញាតឱ្យធ្វើអាជីវកម្មរ៉ែបារតចម្បងដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន រហូតដល់ ១៥ឆ្នាំក្រោយពេលអនុសញ្ញានេះចូលជាធរមាន។ ក្នុងអំឡុងពេលនេះ បារតបានពីការធ្វើអាជីវកម្មរ៉ែបារតចម្បងនេះ ត្រូវប្រើប្រាស់សម្រាប់តែនៅក្នុងផលិតកម្មនៃផលិតផលមានបន្ថែមបារត ដោយអនុលោមតាមមាត្រា៤ សម្រាប់តែនៅក្នុងច្រវ៉ាក់ផលិតកម្មដោយអនុលោមតាមមាត្រា៥ ឬសម្រាប់ការបោះបង់ចោលដោយអនុលោមតាមមាត្រា១១ ដែលដំណើរការនេះមិននាំទៅដល់ការទាញយកមកវិញ ការកែច្នៃឡើងវិញ ការប្រើប្រាស់ឡើងវិញដោយផ្ទាល់ ឬការប្រើជាជម្រើសផ្សេងទៀត។

៥- ភាគីនីមួយៗត្រូវ៖

(ក) កំណត់នូវស្តុកបារតឬសមាសធាតុបារតដែលលើសពី៥០តោន ព្រមទាំងប្រភពផ្គត់ផ្គង់លើសពី១០តោនក្នុងមួយឆ្នាំ ដែលស្ថិតក្នុងដែនដីរបស់ខ្លួន

(ខ) ចាត់វិធានការដើម្បីធានាថាទីតាំងដែលភាគីកំណត់ថាបរិមាណបារតសល់ពីការបញ្ចប់ដំណើរការរោងចក្រផលិតក្លរអាល់កាលី បារតដែលសល់ត្រូវបោះចោលដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់បារតប្រកបដោយសុវត្ថិភាពបរិស្ថាន យោងតាមវាក្យខណ្ឌ៣(ក)នៃមាត្រា១១ ដែលដំណើរការនេះមិននាំទៅដល់ការទាញយកមកវិញ ការកែច្នៃឡើងវិញ ការប្រើប្រាស់ឡើងវិញដោយផ្ទាល់ ឬការប្រើជាជម្រើសផ្សេងទៀត។

៦- ភាគីនីមួយៗមិនអនុញ្ញាតឱ្យនាំចេញបារត លើកលែងតែ៖

(ក) ទៅកាន់ភាគីដែលផ្តល់លិខិតយល់ព្រមដល់ភាគីនាំចេញសម្រាប់តែក្នុងគោលបំណង៖

(១) ការប្រើប្រាស់ដែលទទួលបានការអនុញ្ញាតដល់ភាគីនាំចូលនៅក្រោមអនុសញ្ញានេះ ឬ

(២) ការស្តុកទុកបណ្តោះអាសន្ន ប្រកបដោយសុវត្ថិភាពបរិស្ថានដូចមានចែងក្នុងមាត្រា១០ ឬ

(ខ) ទៅកាន់ប្រទេសមិនមែនជាភាគីដែលផ្តល់លិខិតយល់ព្រមដល់ភាគីនាំចេញ រួមមានលិខិតបញ្ជាក់ថា៖



Media from www.moj.gov.kh resource from www.ocm.gov.kh

(១) ប្រទេសមិនមែនភាគីនោះ មានវិធានការជាធរមានដើម្បីធានាការការពារសុខភាពមនុស្ស និងបរិស្ថាន ព្រមទាំងធានានូវការប្រតិបត្តិដូចមានចែងក្នុងមាត្រា១០និងមាត្រា១១ និង

(២) បារតទាំងនោះត្រូវប្រើប្រាស់សម្រាប់តែចំពោះភាគីដែលទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងអនុសញ្ញានេះប៉ុណ្ណោះ ឬសម្រាប់ការស្តុកបណ្តោះអាសន្នប្រកបដោយសុវត្ថិភាពបរិស្ថានដូចមានចែងក្នុងមាត្រា១០។

៧- ភាគីនាំចេញ អាចយោងលើលិខិតជូនដំណឹងទៅលេខាធិការដ្ឋានដោយភាគីនាំចូលឬលិខិតយល់ព្រមដែលតម្រូវដោយវាក្យខណ្ឌ៦សម្រាប់ប្រទេសមិនមែនជាភាគី។ លិខិតជូនដំណឹងនេះត្រូវកំណត់នូវលក្ខខណ្ឌដែលភាគីនាំចូលឬប្រទេសមិនមែនជាភាគីដែលបានផ្តល់ការយល់ព្រម។ លិខិតជូនដំណឹងនេះអាចដកហូតមកវិញបានគ្រប់ពេលដោយភាគីឬប្រទេសមិនមែនជាភាគីទាំងនោះ។ លេខាធិការដ្ឋាន ត្រូវផ្សព្វផ្សាយជាសាធារណៈនូវគ្រប់លិខិតជូនដំណឹងទាំងនេះ។

៨- ភាគីនីមួយៗ មិនត្រូវអនុញ្ញាតឱ្យនាំចូលបារតពីប្រទេសមិនមែនភាគី ទោះបីបានផ្តល់លិខិតយល់ព្រមហើយក៏ដោយ លុះត្រាតែប្រទេសមិនមែនភាគីបានផ្តល់លិខិតបញ្ជាក់ថាបារតទាំងនោះមិនយកចេញពីប្រភពដែលមិនអនុញ្ញាតដូចបានកំណត់ក្នុងវាក្យខណ្ឌ៣ឬវាក្យខណ្ឌ៥(ខ)។

៩- ភាគីដែលត្រូវផ្តល់លិខិតជូនដំណឹងពីការយល់ព្រមដូចមានចែងក្នុងវាក្យខណ្ឌ៧ អាចសម្រេចមិនអនុវត្តវាក្យខណ្ឌ៨ ដោយត្រូវរក្សានូវការដាក់កម្រិតលើការនាំចេញបារតនិងត្រូវមានវិធានការក្នុងប្រទេសដើម្បីធានាបារតដែលនាំចូលត្រូវបានគ្រប់គ្រងប្រកបដោយសុវត្ថិភាពបរិស្ថាន។ ភាគីត្រូវផ្តល់ការជូនដំណឹងពីសេចក្តីសម្រេចទៅលេខាធិការដ្ឋាន រួមមាន ព័ត៌មានពីការដាក់កម្រិតនាំចេញបារតនិងវិធានការក្នុងស្រុក ក៏ដូចជាព័ត៌មានអំពីបរិមាណនិងប្រទេសដើមនាំចូលបារតពីប្រទេសមិនមែនភាគី។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយជាសាធារណៈនូវគ្រប់លិខិតជូនដំណឹងទាំងនេះ។ គណៈកម្មាធិការប្រតិបត្តិនិងត្រួតពិនិត្យភាពអនុលោម វាយតម្លៃរាល់សេចក្តីជូនដំណឹងនិងព័ត៌មានគាំទ្រដោយអនុលោមតាមមាត្រា១៥ និងផ្តល់អនុសាសន៍ដ៏សមស្របដល់សន្និសីទភាគី។

១០- នីតិវិធីដូចមានចែងក្នុងវាក្យខណ្ឌ៩ ត្រូវបានប្រើប្រាស់រហូតដល់មានសេចក្តីសម្រេចនៃកិច្ចប្រជុំលើកទី២របស់សន្និសីទភាគី។ បន្ទាប់ពីសេចក្តីសម្រេចនៃកិច្ចប្រជុំលើកទី២របស់សន្និសីទភាគី នីតិវិធីនេះនឹងត្រូវបញ្ឈប់ការប្រើប្រាស់លុះត្រាតែសន្និសីទភាគីធ្វើការសម្រេចតាមមតិភាគច្រើននៃវត្តមានរបស់ភាគីនិងការបោះឆ្នោត លើកលែងតែចំពោះភាគីដែលបានផ្តល់សេចក្តីជូនដំណឹងដូចចែងក្នុងវាក្យខណ្ឌ៩ មុនពេលបញ្ចប់កិច្ចប្រជុំលើកទី២នៃសន្និសីទភាគី។

១១- ភាគីនីមួយៗត្រូវបញ្ចូលនូវខ្លឹមសារព័ត៌មានដែលអនុលោមតាមមាត្រា២១ នៅក្នុងរបាយការណ៍របស់ខ្លួនដើម្បីបង្ហាញអំពីតម្រូវការដែលឆ្លើយតបទៅនឹងមាត្រានេះ។

១២- សន្និសីទភាគីនៅក្នុងកិច្ចប្រជុំលើកទី១ត្រូវផ្តល់ការណែនាំបន្ថែមទាក់ទងនឹងមាត្រានេះ ជាពិសេសវាក្យខណ្ឌ៥(ក) វាក្យខណ្ឌ៦ និងវាក្យខណ្ឌ៨ និងត្រូវរៀបចំនិងអនុម័តនូវខ្លឹមសារនៃលិខិតបញ្ជាក់ដូចមានចែងក្នុងវាក្យខណ្ឌ៦(ខ) និងវាក្យខណ្ឌ៨។



Media from www.moj.gov.kh resource from www.ocm.gov.kh

១៣- សន្និសីទភាគី ត្រូវវាយតម្លៃថាតើការធ្វើពាណិជ្ជកម្មសមាសធាតុបារតជាក់លាក់ណាមួយស្របតាមកម្មវត្ថុនៃអនុសញ្ញានេះ និងពិចារណាថាតើសមាសធាតុបារតជាក់លាក់ណាមួយដែលមានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធបន្ថែមដែលត្រូវបានអនុម័តយោងតាមមាត្រា២៧ គួរស្ថិតនៅក្រោមវាក្យខណ្ឌ៦ និងវាក្យខណ្ឌ៨។

## មាត្រា៤
## ផលិតផលមានបន្ថែមបារត

១- ភាគីនីមួយៗ ត្រូវចាត់វិធានការឱ្យបានសមស្រប ដោយមិនត្រូវអនុញ្ញាតឱ្យផលិត នាំចូល ឬនាំចេញនូវផលិតផលមានបន្ថែមបារតដូចបានកំណត់ក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ(ក) នៅក្រោយកាលបរិច្ឆេទបញ្ចប់ដែលបានកំណត់សម្រាប់ផលិតផលទាំងនោះ លើកលែងតែផលិតផលដែលមិនរាប់បញ្ចូលដូចមានចែងក្នុងឧបសម្ព័ន្ធ(ក) ឬក៏ភាគីដែលបានចុះបញ្ជីការលើកលែងដោយអនុលោមតាមមាត្រា៦។

២- ភាគី អាចបង្ហាញប្រាប់ក្នុងអំឡុងពេលការផ្តល់សច្ចាប័នឬការចូលជាធរមាននៃការធ្វើវិសោធនកម្មឧបសម្ព័ន្ធ(ក)ខាងលើនៃអនុសញ្ញានេះនូវជម្រើសផ្សេងពីវាក្យខណ្ឌ១ក្នុងការអនុវត្តនូវវិធានការឬយុទ្ធសាស្ត្រដើម្បីគ្រប់គ្រងផលិតផលដែលបានកំណត់ក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ(ក)។ ភាគី អាចជ្រើសនូវជម្រើសនេះប្រសិនបើអាចបង្ហាញថាវិធានការនេះបានកាត់បន្ថយដល់កម្រិតអប្បបរមានូវការផលិត ការនាំចូល និងការនាំចេញនូវផលិតផលភាគច្រើនដូចបានកំណត់ក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ(ក) និងជម្រើសដែលត្រូវបានអនុវត្តនូវវិធានការឬយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយការប្រើប្រាស់បារតបន្ថែមនៅក្នុងផលិតផលដែលមិនបានកំណត់ក្នុងបញ្ជីក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ(ក) ហើយបានអនុវត្តនូវវិធានការឬយុទ្ធសាស្ត្រកាត់បន្ថយការប្រើប្រាស់បារតក្នុងផលិតផលផ្សេងទៀតដែលមិនបានកំណត់ក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ(ក) នៅពេលជូនដំណឹងដល់លេខាធិការដ្ឋានអំពីសេចក្តីសម្រេចក្នុងការអនុវត្តនូវជម្រើសផ្សេងនោះ។ បន្ថែមពីនេះ ភាគីដែលសម្រេចយកជម្រើសផ្សេងពីវាក្យខណ្ឌ១នេះត្រូវៈ

(ក) ធ្វើរបាយការណ៍នៅឯសន្និសីទភាគីលើកដំបូង ដោយពិពណ៌នាពីវិធានការឬយុទ្ធសាស្ត្រដែលបានអនុវត្តរួមបញ្ចូលបរិមាណនៃការកាត់បន្ថយដែលសម្រេចបាន

(ខ) អនុវត្តវិធានការឬយុទ្ធសាស្ត្រដើម្បីកាត់បន្ថយការប្រើប្រាស់បារតនៅក្នុងផលិតផលដូចបានកំណត់ក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ(ក) ដែលការកាត់បន្ថយបរិមាណជាអប្បបរមាមិនទាន់សម្រេចបាន

(គ) ពិចារណាលើវិធានការផ្សេងទៀតដើម្បីសម្រេចបានការកាត់បន្ថយបរិមាណបារតបន្ថែមទៀត

(ឃ) ពុំមានសិទ្ធិទាមទារការលើកលែងអនុលោមតាមមាត្រា៦ ចំពោះប្រភេទផលិតផលទាំងឡាយណាដែលជម្រើសផ្សេងពីវាក្យខណ្ឌ១នេះត្រូវបានប្រើប្រាស់។

អនុលោមតាមដំណើរការត្រួតពិនិត្យស្ថិតក្រោមវាក្យខណ្ឌ៨ សន្និសីទភាគីត្រូវធ្វើការពិនិត្យអំពីវឌ្ឍនភាពនិងប្រសិទ្ធភាពនៃវិធានការនានា ដែលបានអនុវត្តស្ថិតក្រោមវាក្យខណ្ឌនេះមិនឱ្យលើសពីរយៈពេល៥ឆ្នាំក្រោយពេលអនុសញ្ញានេះចូលជាធរមាន។

៣- ភាគីនីមួយៗ ត្រូវចាត់វិធានការចំពោះផលិតផលមានបន្ថែមបារត ដែលបានកំណត់ក្នុងផ្នែកទី២នៃឧបសម្ព័ន្ធ(ក) ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។



Media from www.moj.gov.kh resource from www.ocm.gov.kh

៤- ដោយផ្អែកលើព័ត៌មានដែលបានផ្តល់ដោយភាគី លេខាធិការដ្ឋានត្រូវប្រមូលនិងរក្សាទុកព័ត៌មានស្តីពីផលិតផលមានបន្ថែមបារតនិងផលិតផលជំនួស ហើយត្រូវផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាំងនេះ។ លេខាធិការដ្ឋានក៏ត្រូវផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធផ្សេងៗដែលភាគីបានផ្តល់ឱ្យ។

៥- ភាគីនីមួយៗ ត្រូវចាត់វិធានការទប់ស្កាត់ការផលិត ការនាំចូល និងនាំចេញនូវផលិតផលបង្គុំមានបន្ថែមបារតដែលមិនត្រូវបានអនុញ្ញាតអនុលោមតាមមាត្រានេះ។

៦- ភាគីនីមួយៗ មិនត្រូវលើកទឹកចិត្តដល់ការផលិតនិងការចែកចាយ សម្រាប់ការធ្វើពាណិជ្ជកម្មនូវផលិតផលមានបន្ថែមបារតដែលមិនស្ថិតនៅក្រោមប្រភេទផលិតផលមានបន្ថែមបារត ដែលធ្លាប់បានស្គាល់ មុនកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ លុះត្រាតែមានការវាយតម្លៃពីហានិភ័យនិងគុណប្រយោជន៍របស់ផលិតផលចំពោះបរិស្ថាននិងសុខភាព។ ភាគី ត្រូវផ្តល់ទៅលេខាធិការដ្ឋានតាមការគួរ នូវព័ត៌មានស្តីពីប្រភេទផលិតផលទាំងនេះ រួមមានព័ត៌មានអំពីហានិភ័យដល់បរិស្ថាននិងសុខភាពមនុស្ស ព្រមទាំងគុណប្រយោជន៍នៃផលិតផលទាំងនេះ។ លេខាធិការដ្ឋាន ត្រូវផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាំងនេះ។

៧- ភាគីនីមួយៗ អាចដាក់សំណើទៅលេខាធិការដ្ឋាន សម្រាប់ការចុះបញ្ជីផលិតផលមានបន្ថែមបារតក្នុងឧបសម្ព័ន្ធ(ក) ដែលត្រូវបញ្ចូលនូវព័ត៌មានដែលទាក់ទងនឹងការអាចរកបាន ភាពដែលអាចធ្វើបានខាងបច្ចេកទេសនិងសេដ្ឋកិច្ច និងហានិភ័យបរិស្ថាននិងសុខភាព និងគុណប្រយោជន៍នៃផលិតផលជំនួសដែលគ្មានបារត ដោយពិចារណានូវព័ត៌មានដែលអនុលោមតាមវាក្យខណ្ឌ៤។

៨- មិនលើសពីរយៈពេល៥ឆ្នាំក្រោយកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ សន្និសីទភាគីត្រូវត្រួតពិនិត្យឡើងវិញនូវឧបសម្ព័ន្ធ(ក) និងពិចារណាលើការធ្វើវិសោធនកម្មឧបសម្ព័ន្ធនេះដោយអនុលោមតាមមាត្រា២៧។

៩- យោងតាមវាក្យខណ្ឌ៨ នៅក្នុងការត្រួតពិនិត្យឡើងវិញឧបសម្ព័ន្ធ(ក) សន្និសីទភាគីត្រូវធ្វើការពិចារណាយ៉ាងហោចណាស់លើ៖

(ក) សំណើទាំងឡាយណាដែលបានស្នើនៅក្រោមវាក្យខណ្ឌ៧

(ខ) ព័ត៌មានដែលផ្សព្វផ្សាយជាសាធារណៈដោយអនុលោមតាមវាក្យខណ្ឌ៤ និង

(គ) ភាពដែលអាចមាននូវផលិតផលជំនួសដែលគ្មានបារតដែលអាចធ្វើបានខាងបច្ចេកទេសនិងសេដ្ឋកិច្ច ដោយពិចារណានូវហានិភ័យនិងគុណប្រយោជន៍ចំពោះបរិស្ថាននិងសុខភាពមនុស្ស។

## មាត្រា៥
## ប្រព័ន្ធផលិតកម្មដែលប្រើបារតឬសមាសធាតុបារត

១- សម្រាប់គោលបំណងនៃមាត្រានេះនិងឧបសម្ព័ន្ធ(ខ) ប្រព័ន្ធផលិតកម្មដែលប្រើបារតឬសមាសធាតុបារត មិនត្រូវរាប់បញ្ចូលនូវប្រព័ន្ធផលិតកម្មមានប្រើប្រាស់ផលិតផលមានបន្ថែមបារត ប្រព័ន្ធផលិតកម្មសម្រាប់ផលិតផលិតផលមានបន្ថែមបារត ឬប្រព័ន្ធផលិតកម្មដែលធ្វើប្រព្រឹត្តកម្មសំណល់មានផ្ទុកបារត។

២- ភាគីនីមួយៗដោយចាត់វិធានការឱ្យបានសមស្រប មិនត្រូវអនុញ្ញាតឱ្យប្រើប្រាស់បារតឬសមាសធាតុបារតនៅក្នុងច្រវ៉ាក់ផលិតកម្មនីមួយៗនៃដំណើរការផលិតកម្មដូចបានកំណត់ក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ(ខ) នៅក្រោយកាលបរិច្ឆេទបញ្ឈប់ដំណើរការផលិតកម្មនៃផលិតផលដែលបានកំណត់ក្នុងឧបសម្ព័ន្ធនេះ លើកលែងតែភាគីនោះត្រូវបានចុះបញ្ជីសុំការលើកលែងដោយអនុលោមតាមមាត្រា៦។

៣- ភាគីនីមួយៗ ត្រូវចាត់វិធានការដើម្បីរឹតបន្តឹងការប្រើប្រាស់បារតឬសមាសធាតុបារតនៅក្នុងច្រវ៉ាក់ផលិតកម្មដូចបានកំណត់ក្នុងផ្នែកទី២នៃឧបសម្ព័ន្ធ(ខ) ដោយអនុលោមតាមបទប្បញ្ញត្តិដែលមានចែងក្នុងអនុសញ្ញានេះ។

៤- លេខាធិការដ្ឋានដោយផ្អែកលើព័ត៌មានដែលទទួលបានពីភាគី ត្រូវប្រមូលនិងថែរក្សាព័ត៌មានស្តីពីច្រវ៉ាក់ផលិតកម្មដែលប្រើប្រាស់បារតឬសមាសធាតុបារត និងផលិតផលជំនួស ហើយត្រូវធ្វើការផ្សព្វផ្សាយនូវព័ត៌មានទាំងនោះជាសាធារណៈ។ ព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលភាគីបានផ្តល់ឱ្យលេខាធិការដ្ឋានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ។

៥- ភាគីនីមួយៗដែលមានទីតាំងផលិតកម្មមួយឬច្រើន មានប្រើប្រាស់បារតឬសមាសធាតុបារតនៅក្នុងច្រវ៉ាក់ផលិតកម្មដូចបានកំណត់ក្នុងឧបសម្ព័ន្ធ(ខ)ត្រូវៈ

(ក) ចាត់វិធានការកាត់បន្ថយការបញ្ចេញនិងការសាយភាយនូវបារតឬសមាសធាតុបារត ពីទីតាំងផលិតកម្មទាំងនោះ

(ខ) អនុលោមតាមមាត្រា២១ របាយការណ៍ដែលត្រូវបានផ្តល់ឱ្យត្រូវដាក់បញ្ចូលនូវព័ត៌មានស្តីពីវិធានការដែលបានជ្រើសរើសដោយអនុលោមតាមវាក្យខណ្ឌនេះ និង

(គ) កំណត់អត្តសញ្ញាណទីតាំងផលិតកម្មក្នុងដែនដីរបស់ខ្លួនដែលប្រើប្រាស់បារតឬសមាសធាតុបារតសម្រាប់ច្រវ៉ាក់ផលិតកម្មដូចបានកំណត់ក្នុងឧបសម្ព័ន្ធ(ខ) និងត្រូវផ្ញើទៅលេខាធិការដ្ឋានមិនឱ្យលើសពី៣ឆ្នាំក្រោយកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ នូវព័ត៌មានស្តីពីចំនួននិងប្រភេទនៃទីតាំងផលិតកម្ម និងបរិមាណប៉ាន់ស្មានប្រចាំឆ្នាំនៃការប្រើប្រាស់បារតឬសមាសធាតុបារត។ លេខាធិការដ្ឋានត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈ។

៦- ភាគីនីមួយៗ មិនត្រូវអនុញ្ញាតឱ្យប្រើប្រាស់បារតឬសមាសធាតុបារតនៅក្នុងច្រវ៉ាក់ផលិតកម្មដែលបានកំណត់ក្នុងឧបសម្ព័ន្ធ(ខ) សម្រាប់ទីតាំងផលិតកម្មដែលបង្កើតក្រោយកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ។ ពុំមានការលើកលែងណាមួយ ត្រូវបានផ្តល់ឱ្យទីតាំងផលិតកម្មនេះទេ។

៧- ភាគីនីមួយៗ មិនត្រូវលើកទឹកចិត្តដល់ការបង្កើតទីតាំងផលិតកម្មដែលប្រើប្រាស់បារតឬសមាសធាតុបារតដោយចេតនានៅក្នុងច្រវ៉ាក់ផលិតកម្មក្រោយពេលអនុសញ្ញានេះចូលជាធរមាន លើកលែងតែភាគីអាចបញ្ជាក់ដល់សន្និសីទភាគីថាច្រវ៉ាក់ផលិតកម្មនោះផ្តល់អត្ថប្រយោជន៍ច្រើនដល់បរិស្ថាននិងសុខភាពមនុស្ស ហើយពុំមានជម្រើសជំនួសបារតណាមួយ អាចប្រើប្រាស់បានតាមលក្ខណៈបច្ចេកទេសនិងសេដ្ឋកិច្ចដែលផ្តល់អត្ថប្រយោជន៍ដូចគ្នានេះ។

៨– ភាគីទាំងអស់ ត្រូវបានលើកទឹកចិត្តដល់ការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការអភិវឌ្ឍបច្ចេកវិទ្យាថ្មី ជម្រើសបច្ចេកទេសនិងសេដ្ឋកិច្ចដែលអាចធ្វើបានដោយពុំមានប្រើប្រាស់បារត និងវិធានការនិងបច្ចេកទេសដែលអាចអនុវត្តបានដើម្បីកាត់បន្ថយការបញ្ចេញនិងការសាយភាយ ព្រមទាំងដើម្បីលុបបំបាត់ការប្រើប្រាស់បារតនិងសមាសធាតុបារតក្នុងប្រព័ន្ធផលិតកម្មដូចមានចែងក្នុងឧបសម្ព័ន្ធ(ខ)។

៩– ភាគីនីមួយៗ អាចស្នើសុំធ្វើវិសោធនកម្មឧបសម្ព័ន្ធ(ខ) ដើម្បីកំណត់ប្រភេទប្រព័ន្ធផលិតកម្មដែលប្រើប្រាស់បារតឬសមាសធាតុបារត។ សំណើនេះ ត្រូវបញ្ចូលនូវព័ត៌មានពាក់ព័ន្ធនឹងភាពដែលអាចរកបាន ភាពអាចធ្វើបានតាមបច្ចេកទេសនិងសេដ្ឋកិច្ច ព្រមទាំងហានិភ័យបរិស្ថាននិងសុខភាព និងអត្ថប្រយោជន៍នៃជម្រើសមិនប្រើបារតនៅក្នុងប្រព័ន្ធផលិតកម្ម។

១០– សន្និសីទភាគីត្រូវពិនិត្យឧបសម្ព័ន្ធ(ខ)ឡើងវិញ និងអាចពិចារណាធ្វើវិសោធនកម្មឧបសម្ព័ន្ធនេះ ដោយអនុលោមតាមមាត្រា២៧ មិនលើសពីរយៈពេល៥ឆ្នាំក្រោយកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ។

១១– យោងតាមវាក្យខណ្ឌ១០ នៅក្នុងការត្រួតពិនិត្យឡើងវិញឧបសម្ព័ន្ធ(ខ) សន្និសីទភាគីត្រូវធ្វើការពិចារណាយ៉ាងហោចណាស់លើ៖

(ក) សំណើទាំងឡាយណាដែលបានស្នើនៅក្រោមវាក្យខណ្ឌ៩

(ខ) ព័ត៌មានដែលផ្សព្វផ្សាយជាសាធារណៈដោយអនុលោមតាមវាក្យខណ្ឌ៤ និង

(គ) ភាពដែលអាចមាននូវផលិតផលជំនួសដែលគ្មានបារត ដែលអាចធ្វើបានតាមលក្ខខណ្ឌបច្ចេកទេសនិងសេដ្ឋកិច្ច ដោយពិចារណានូវហានិភ័យនិងអត្ថប្រយោជន៍ចំពោះបរិស្ថាននិងសុខភាពមនុស្ស។

## មាត្រា៦
## ការផ្តល់ការលើកលែងដល់ភាគីស្នើសុំ

១– រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចស្នើសុំចុះបញ្ជីការលើកលែងមួយឬច្រើនសម្រាប់កាលបរិច្ឆេទបញ្ឈប់ការប្រើប្រាស់បារតឬសមាសធាតុបារតដូចបានកំណត់ក្នុងឧបសម្ព័ន្ធ(ក)និង(ខ) ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន៖

(ក) ពេលចូលជាភាគីនៃអនុសញ្ញានេះ ឬ

(ខ) ក្នុងករណីផលិតផលមានបន្ថែមបារត ត្រូវធ្វើវិសោធនកម្មដាក់បញ្ចូលបន្ថែមក្នុងឧបសម្ព័ន្ធ(ក) ឬប្រព័ន្ធផលិតកម្មប្រើប្រាស់បារតត្រូវធ្វើវិសោធនកម្មដាក់បញ្ចូលបន្ថែមក្នុងឧបសម្ព័ន្ធ(ខ) មិនឱ្យយឺតជាងកាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្មសម្រាប់ភាគីទាំងអស់។

រាល់ការស្នើសុំចុះបញ្ជីបែបនេះ ត្រូវភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍ដែលពន្យល់ពីតម្រូវការរបស់ភាគីសម្រាប់ការសុំលើកលែង។

២– ការលើកលែង អាចត្រូវចុះបញ្ជីទាំងផ្នែកដែលបានកំណត់ក្នុងឧបសម្ព័ន្ធ(ក)ឬឧបសម្ព័ន្ធ(ខ) ឬសម្រាប់អនុផ្នែកដែលបានកំណត់ដោយរដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់។

៣– ភាគីនីមួយៗដែលទទួលបានការលើកលែងមួយឬច្រើន នឹងត្រូវបានកំណត់នៅក្នុងបញ្ជី។ លេខាធិការដ្ឋានត្រូវរៀបចំបង្កើតនិងរក្សាបញ្ជីនេះ ព្រមទាំងផ្សព្វផ្សាយជាសាធារណៈ។



Media from www.moj.gov.kh resource from www.ocm.gov.kh

៤- បញ្ជីនេះត្រូវមានបញ្ចូលនូវ៖

(ក) តារាងបញ្ជីភាគីដែលទទួលការលើកលែងមួយឬច្រើន

(ខ) ការលើកលែងមួយឬច្រើនដែលបានចុះបញ្ជីសម្រាប់ភាគីនីមួយៗ និង

(គ) សុពលភាពនៃការសុំលើកលែង។

៥- លុះត្រាតែភាគីបានបញ្ជាក់ពីការលើកលែងមានរយៈពេលខ្លីនៅក្នុងបញ្ជី រាល់ការលើកលែងដែលអនុលោមតាមវាក្យខណ្ឌ១ត្រូវអស់សុពលភាពរយៈពេល៥ឆ្នាំ ក្រោយកាលបរិច្ឆេទពាក់ព័ន្ធទៅនឹងការបញ្ឈប់ការប្រើប្រាស់បារតនិងសមាសធាតុបារតដែលមានកំណត់ក្នុងឧបសម្ព័ន្ធ(ក)និង(ខ)។

៦- សន្និសីទភាគីតាមការស្នើសុំរបស់ភាគី អាចសម្រេចពន្យារពេលការសុំលើកលែងសម្រាប់រយៈពេល៥ឆ្នាំបន្ត លុះត្រាតែភាគីស្នើសុំបន្តរយៈពេលខ្លី។ ក្នុងការធ្វើសេចក្តីសម្រេច សន្និសីទភាគីត្រូវពិចារណាលើ៖

(ក) របាយការណ៍ពីភាគីដែលបញ្ជាក់ពីតម្រូវការដើម្បីពន្យារសុំការលើកលែងនិងផែនការសកម្មភាពដែលត្រូវអនុវត្តនិងគ្រោងដើម្បីបញ្ឈប់តម្រូវការសម្រាប់ការសុំលើកលែងតាមតែអាចធ្វើបាន

(ខ) ព័ត៌មានដែលអាចរកបាន រួមមានព័ត៌មាននៃភាពដែលអាចរកបានទាក់ទងនឹងផលិតផលនិងច្រវ៉ាក់ផលិតកម្មជំនួសដែលមិនមានបារតឬប្រើប្រាស់បារតតិចជាងបរិមាណដែលលើកលែង និង

(គ) សកម្មភាពដែលបានគ្រោងឬកំពុងអនុវត្តដែលធានានូវការស្តុកទុកបារតឬការបោះចោលសំណល់បារតប្រកបដោយសុវត្ថិភាពបរិស្ថាន។

ការសុំលើកលែង អាចត្រូវបានពន្យារតែម្តងក្នុងផលិតផលមួយចំពោះកាលបរិច្ឆេទបញ្ឈប់ម្តង។

៧- ភាគី អាចដកការលើកលែងនៅពេលណាក៏បាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន។ ការដកការលើកលែង នឹងមានសុពលភាពចាប់ពីថ្ងៃជូនដំណឹងដែលបានកំណត់នៅក្នុងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរនោះ។

៨- ទោះបីមានចែងក្នុងវាក្យខណ្ឌ១ក៏ដោយ ពុំមានរដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់អាចចុះបញ្ជីស្នើសុំការលើកលែងក្រោយពីរយៈពេល៥ឆ្នាំនៃកាលបរិច្ឆេទបញ្ឈប់សម្រាប់ផលិតផលឬច្រវ៉ាក់ផលិតកម្មដូចមានចែងក្នុងឧបសម្ព័ន្ធ(ក)ឬឧបសម្ព័ន្ធ(ខ) លើកលែងតែភាគីមួយឬច្រើននៅចុះបញ្ជីសម្រាប់ការសុំលើកលែងលើផលិតផលឬច្រវ៉ាក់ផលិតកម្ម ដោយបានទទួលការបន្តលើកលែងដោយអនុលោមតាមវាក្យខណ្ឌទី៦។ ក្នុងករណីនោះ រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចចុះបញ្ជីស្នើសុំការលើកលែងចំពោះផលិតផល ឬច្រវ៉ាក់ផលិតកម្មដូចមានកំណត់នៅក្នុងវាក្យខណ្ឌ១(ក)និង(ខ) ដែលនឹងត្រូវអស់សុពលភាពក្រោយរយៈពេល១០ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទបញ្ឈប់សម្រាប់ផលិតផលឬច្រវ៉ាក់ផលិតកម្ម។

៩- ពុំមានភាគីណា អាចទទួលបានការលើកលែងក្រោយរយៈពេល១០ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទបញ្ឈប់សម្រាប់ផលិតផលឬច្រវ៉ាក់ផលិតកម្មដូចដែលបានកំណត់ក្នុងឧបសម្ព័ន្ធ(ក)ឬឧបសម្ព័ន្ធ(ខ)។



Media from www.moj.gov.kh resource from www.ocm.gov.kh

## មាត្រា៧
## អាជីវកម្មរ៉ែមាសខ្នាតតូច

១- រាល់វិធានការដែលបានកំណត់នៅក្នុងមាត្រានេះនិងឧបសម្ព័ន្ធ(គ) ត្រូវអនុវត្តចំពោះអាជីវកម្មរ៉ែមាសខ្នាតតូចនិងប្រវ៉ាក់ផលិតកម្មដែលបារតត្រូវបានប្រើប្រាស់សម្រាប់ចាប់យកមាសចេញពីរ៉ែ។

២- ភាគីនីមួយៗដែលមានសកម្មភាពអាជីវកម្មរ៉ែមាសខ្នាតតូចនិងដំណើរការផលិតកម្ម ដែលបញ្ញត្តិក្នុងមាត្រានេះដែលស្ថិតក្នុងដែនដីរបស់ខ្លួន បើអាចធ្វើទៅបានត្រូវចាត់វិធានការដើម្បីកាត់បន្ថយឬលុបបំបាត់ចំពោះការប្រើប្រាស់បារតនិងសមាសធាតុបារត ការបញ្ចេញ និងការសាយភាយបារតចូលទៅក្នុងបរិស្ថានពីសកម្មភាពអាជីវកម្មរ៉ែមាសនិងដំណើរការផលិតកម្ម។

៣- ភាគីនីមួយៗ ត្រូវជូនដំណឹងទៅលេខាធិការដ្ឋាន នៅពេលណាភាគីបញ្ជាក់ថាអាជីវកម្មរ៉ែមាសខ្នាតតូចនិងដំណើរការផលិតកម្ម ស្ថិតក្នុងដែនដីរបស់ខ្លួនមានចំនួនច្រើន។ ភាគីត្រូវ៖

(ក) រៀបចំនិងអនុវត្តផែនការសកម្មភាពជាតិដោយអនុលោមតាមឧបសម្ព័ន្ធ(គ)

(ខ) ផ្តល់ផែនការសកម្មភាពជាតិទៅលេខាធិការដ្ឋានមិនហួសពីរយៈពេល៣ឆ្នាំក្រោយពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះឬ៣ឆ្នាំក្រោយពីការជូនដំណឹងទៅលេខាធិការដ្ឋាន និង

(គ) បន្ទាប់មកផ្តល់ការត្រួតពិនិត្យឡើងវិញរៀងរាល់៣ឆ្នាំពីវឌ្ឍនភាពក្នុងការអនុវត្តកាតព្វកិច្ច ដូចមានចែងនៅក្នុងមាត្រានេះ និងដាក់បញ្ចូលលទ្ធផលនៃការត្រួតពិនិត្យឡើងវិញនៅក្នុងរបាយការណ៍ដែលត្រូវផ្តល់ដោយអនុលោមតាមមាត្រា២១។

៤- ភាគី អាចសហការជាមួយភាគីផ្សេងទៀតឬអង្គការអន្តររដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមតែអាចធ្វើទៅបាន ដើម្បីសម្រេចបាននូវកម្មវត្ថុនៃមាត្រានេះ។ កិច្ចសហការនេះអាចជា៖

(ក) ការរៀបចំយុទ្ធសាស្ត្រទប់ស្កាត់ការប្រើប្រាស់បារត និងសមាសធាតុបារតក្នុងការធ្វើអាជីវកម្មរ៉ែមាសខ្នាតតូចនិងដំណើរការផលិតកម្ម

(ខ) គំនិតផ្តួចផ្តើមសម្រាប់ការអប់រំ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

(គ) ជំរុញការសិក្សាស្រាវជ្រាវអំពីវិធីសាស្ត្រនៃការធ្វើអាជីវកម្មរ៉ែមាសខ្នាតតូច ប្រកបដោយចីរភាពដោយមិនមានការប្រើប្រាស់បារត

(ឃ) ការផ្តល់នូវជំនួយជាបច្ចេកទេសនិងហិរញ្ញវត្ថុ

(ង) ភាពជាដៃគូសម្រាប់ជួយនៅក្នុងការអនុវត្តនូវការប្តេជ្ញារបស់ខ្លួនក្រោមមាត្រានេះ និង

(ច) ការប្រើប្រាស់នូវយន្តការចែករំលែកព័ត៌មានដែលមានស្រាប់ ដើម្បីលើកកម្ពស់ការយល់ដឹងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរនិងបច្ចេកវិទ្យាជំនួសដែលមានលក្ខណៈបរិស្ថានសមស្របតាមលក្ខខណ្ឌបច្ចេកទេស សង្គម និងសេដ្ឋកិច្ច ។

## មាត្រា៨

## ការបញ្ចេញ

១- មាត្រានេះ ផ្តោតលើការត្រួតពិនិត្យនិងកាត់បន្ថយការបញ្ចេញបារតនិងសមាសធាតុបារត ដែលសំដៅដល់ « បារតសរុប » ចូលទៅក្នុងបរិយាកាសតាមរយៈវិធានការត្រួតពិនិត្យការបញ្ចេញពីប្រភពអចល័តដែលស្ថិតនៅក្នុងក្រុមប្រភពដូចមានចែងក្នុងឧបសម្ព័ន្ធ(ឃ)។

២- សម្រាប់គោលបំណងនៃមាត្រានេះ៖

(ក) « ការបញ្ចេញ » សំដៅដល់ការបញ្ចេញបារតឬសមាសធាតុបារតចូលទៅក្នុងបរិយាកាស

(ខ) « ប្រភពដែលពាក់ព័ន្ធ » សំដៅដល់ប្រភពមួយដែលស្ថិតនៅក្នុងចំណោមក្រុមប្រភពដូចមានចែងក្នុងឧបសម្ព័ន្ធ(ឃ)។ ភាគី អាចបង្កើតលក្ខណៈវិនិច្ឆ័យជ្រើសរើសដើម្បីកំណត់ប្រភពមួយដែលស្ថិតនៅក្នុងចំណោមក្រុមប្រភពដូចមានចែងក្នុងឧបសម្ព័ន្ធ(ឃ) លុះត្រាលក្ខណៈវិនិច្ឆ័យសម្រាប់ក្រុមប្រភពណាមួយដែលបញ្ចេញបារតយ៉ាងតិច៧៥ភាគរយពីក្រុមប្រភពទាំងនោះ

(គ) « ប្រភពថ្មី » សំដៅដល់ប្រភពដែលពាក់ព័ន្ធទាំងឡាយស្ថិតនៅក្នុងក្រុមប្រភពដូចមានចែងក្នុងឧបសម្ព័ន្ធ(ឃ) ការសាងសង់និងការកែប្រែក្នុងទ្រង់ទ្រាយធំដែលធ្វើឡើងយ៉ាងតិច១ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទ៖

(១) ចូលជាធរមាននៃអនុសញ្ញានេះសម្រាប់ភាគីពាក់ព័ន្ធ ឬ

(២) ចូលជាធរមានសម្រាប់ភាគីពាក់ព័ន្ធនៃវិសោធនកម្មឧបសម្ព័ន្ធ(ឃ) ដែលប្រភពបញ្ចេញដូចបញ្ញត្តិនៅក្នុងអនុសញ្ញានេះដោយសារការធ្វើវិសោធនកម្មប៉ុណ្ណោះ។

(ឃ) « ការកែប្រែក្នុងទ្រង់ទ្រាយធំ » សំដៅដល់ការកែប្រែប្រភពដែលពាក់ព័ន្ធបង្កឱ្យមានការកើនឡើងនូវការបញ្ចេញដោយមិនរាប់បញ្ចូលនូវការផ្លាស់ប្តូរណាមួយនៅក្នុងការបញ្ចេញដែលបង្កមកពីការទាញយកមកវិញពីផលិតផលបន្ទាប់បន្សំ។ ភាគីអាចធ្វើការសម្រេចថា តើការកែប្រែមានលក្ខណៈទ្រង់ទ្រាយធំឬក៏មិនមាន។

(ង) « ប្រភពមានស្រាប់ » សំដៅដល់ប្រភពដែលពាក់ព័ន្ធដែលមិនមែនជាប្រភពថ្មី

(ច) « កម្រិតកំណត់នៃការបញ្ចេញ » សំដៅដល់កម្រិតកំណត់កំហាប់ ម៉ាស ឬអត្រាបញ្ចេញនៃបារតឬសមាសធាតុបារតដែលសំដៅដល់ « បារតសរុប » បញ្ចេញពីប្រភពអចល័ត។

៣- ភាគីមានប្រភពដែលពាក់ព័ន្ធ ត្រូវចាត់វិធានការត្រួតពិនិត្យការបញ្ចេញនិងរៀបចំផែនការជាតិដែលដាក់ចេញនូវវិធានការត្រួតពិនិត្យការបញ្ចេញនិងទិសដៅ គោលដៅនិងលទ្ធផលរំពឹងទុក។ ផែនការជាតិត្រូវដាក់ជូនទៅសន្និសីទភាគីនៅក្នុងរយៈពេល៤ឆ្នាំ ក្រោយកាលបរិច្ឆេទចូលជាធរមាននៃការផ្តល់សច្ចាប័នរបស់ភាគី។ ប្រសិនបើភាគីមួយរៀបចំផែនការអនុវត្តដោយយោងតាមមាត្រា២០ ភាគីនោះអាចរាប់បញ្ចូលទៅក្នុងផែនការដែលបានរៀបចំដោយអនុលោមតាមវាក្យខណ្ឌនេះ។

៤- សម្រាប់ប្រភពថ្មីរបស់ខ្លួន ភាគីនីមួយៗនឹងតម្រូវឱ្យប្រើប្រាស់នូវបច្ចេកទេសដ៏ប្រសើរដែលអាចរកបាននិងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ ដើម្បីត្រួតពិនិត្យនិងកាត់បន្ថយការបញ្ចេញតាមតែអាចធ្វើទៅបាន ប៉ុន្តែ

មិនលើសពី៥ឆ្នាំក្រោយពេលចូលជាធរមាននៃអនុសញ្ញានេះសម្រាប់ភាគីនោះ។ ភាគី អាចប្រើប្រាស់កម្រិតកំណត់ការបញ្ចេញដែលស្របទៅនឹងការអនុវត្តបច្ចេកទេសដ៏ប្រសើរដែលអាចរកបាន។

៥– សម្រាប់ប្រភពដែលមានស្រាប់ ភាគីត្រូវដាក់បញ្ចូលនៅក្នុងផែនការជាតិ ហើយនឹងត្រូវអនុវត្តវិធានការមួយឬច្រើនដូចខាងក្រោម តាមពេលវេលាដែលអនុវត្តបានមិនឱ្យលើសពីរយៈពេល១០ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះដោយគិតគូរទៅលើស្ថានភាពប្រទេសនិងវិធានការដែលមានលក្ខណៈសមស្របទៅនឹងសេដ្ឋកិច្ចនិងបច្ចេកទេស៖

(ក) គោលដៅកម្រិតកំណត់នៃការបញ្ចេញសម្រាប់ត្រួតពិនិត្យ និងកាត់បន្ថយការបញ្ចេញពីប្រភពដែលពាក់ព័ន្ធ

(ខ) កម្រិតកំណត់ការបញ្ចេញសម្រាប់ត្រួតពិនិត្យនិងកាត់បន្ថយការបញ្ចេញពីប្រភពដែលពាក់ព័ន្ធ

(គ) ការប្រើប្រាស់បច្ចេកទេសដ៏ប្រសើរដែលអាចរកបាននិងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ ដើម្បីត្រួតពិនិត្យការបញ្ចេញពីប្រភពដែលពាក់ព័ន្ធ

(ឃ) យុទ្ធសាស្ត្រត្រួតពិនិត្យសារធាតុបំពុលចម្រុះដែលអាចផ្តល់នូវអត្ថប្រយោជន៍រួមសម្រាប់ត្រួតពិនិត្យការបញ្ចេញបារត

(ង) វិធានការជំនួសដើម្បីកាត់បន្ថយការបញ្ចេញពីប្រភពដែលពាក់ព័ន្ធ។

៦– ភាគីទាំងអស់ អាចអនុវត្តវិធានការដូចគ្នាចំពោះប្រភពដែលពាក់ព័ន្ធមានស្រាប់ឬអាចជ្រើសយកវិធានការដោយឡែកចំពោះក្រុមប្រភពផ្សេងគ្នា។ គោលដៅដែលភាគីបានអនុវត្តវិធានការនេះ សំដៅសម្រេចបាននូវវឌ្ឍនភាពក្នុងការកាត់បន្ថយការបញ្ចេញបារតតាមពេលវេលាកំណត់ណាមួយ។

៧– ភាគីនីមួយៗ ត្រូវរៀបចំនិងរក្សាទុករបាយការណ៍សារពើភណ្ឌស្តីពីការបញ្ចេញបារតពីប្រភពដែលពាក់ព័ន្ធតាមពេលដែលអាចធ្វើបាន និងមិនឱ្យលើសពីរយៈពេល៥ឆ្នាំក្រោយកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នអនុសញ្ញានេះ។

៨– នៅក្នុងកិច្ចប្រជុំលើកទី១ សន្និសីទភាគីត្រូវអនុម័តគោលការណ៍ស្តីពី៖

(ក) បច្ចេកទេសដ៏ល្អប្រសើរដែលអាចរកបាននិងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរដោយគិតគូរទៅលើភាពខុសគ្នារវាងប្រភពថ្មីនិងប្រភពដែលមានស្រាប់ ព្រមទាំងតម្រូវការដើម្បីកាត់បន្ថយឱ្យដល់អប្បបរមានៃទំហំផលប៉ះពាល់ទៅស្ថានប្រព័ន្ធបរិស្ថាន(ទឹក ដី ខ្យល់) និង

(ខ) ការគាំទ្រដល់ភាគីក្នុងការអនុវត្តវិធានការដូចបានកំណត់ក្នុងវាក្យខណ្ឌ៥ ជាពិសេសក្នុងការកំណត់គោលដៅនិងកម្រិតកំណត់ការបញ្ចេញ។

៩– សន្និសីទភាគី តាមតែអាចធ្វើបានត្រូវអនុម័តគោលការណ៍ស្តីពី៖

(ក) លក្ខណៈវិនិច្ឆ័យដែលភាគីរៀបចំកំណត់ប្រភពដែលពាក់ព័ន្ធដូចមានចែងក្នុងវាក្យខណ្ឌ២(ខ)

(ខ) វិធីសាស្ត្រសម្រាប់រៀបចំរបាយការណ៍សារពើភ័ណ្ឌនៃការបញ្ចេញបារត។



Media from www.moj.gov.kh resource from www.ocm.gov.kh

១០- សន្និសីទភាគី ត្រូវត្រួតពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពតាមដែលអាចធ្វើបានលើគោលការណ៍ដែលបានរៀបចំដូចមានចែងក្នុងវាក្យខណ្ឌ៨ និងវាក្យខណ្ឌ៩។ ភាគីទាំងអស់ ត្រូវអនុវត្តបញ្ញត្តិដែលមានចែងក្នុងមាត្រានេះ ដោយផ្អែកលើគោលការណ៍ណែនាំនេះ។

១១- ភាគីនីមួយៗ ត្រូវដាក់បញ្ចូលព័ត៌មាននៃការអនុវត្តមាត្រានេះទៅក្នុងរបាយការណ៍ដែលត្រូវផ្តល់ជូនលេខាធិការដ្ឋានដូចមានចែងក្នុងមាត្រា២១ ជាពិសេសព័ត៌មានដែលទាក់ទងទៅនឹងវិធានការដែលភាគីបានអនុវត្តដោយអនុលោមតាមវាក្យខណ្ឌ៤ដល់វាក្យខណ្ឌ៧ និងប្រសិទ្ធភាពនៃវិធានការទាំងនោះ។

## មាត្រា៩
## ការសាយភាយ

១- មាត្រានេះ ផ្តោតលើការត្រួតពិនិត្យនិងកាត់បន្ថយការសាយភាយបារតនិងសមាសធាតុបារតដែលសំដៅដល់ « បារតសរុប » ចូលទៅក្នុងដីនិងទឹកពីប្រភពអចល័តដែលពាក់ព័ន្ធដោយមិនមានចែងនៅក្នុងបញ្ញត្តិផ្សេងទៀតនៃអនុសញ្ញានេះ។

២- សម្រាប់គោលបំណងនៃមាត្រានេះ៖

(ក) « ការសាយភាយ » សំដៅដល់ការសាយភាយបារតឬសមាសធាតុបារតចូលទៅក្នុងដីឬទឹក

(ខ) « ប្រភពដែលពាក់ព័ន្ធ » សំដៅដល់ប្រភពសាយភាយអចល័តដែលបង្កឡើងដោយសកម្មភាពដូចបានកំណត់ដោយភាគីដែលមិនមានចែងក្នុងបញ្ញត្តិផ្សេងទៀតនៃអនុសញ្ញានេះ

(គ) « ប្រភពថ្មី » សំដៅដល់ប្រភពដែលពាក់ព័ន្ធការសាងសង់និងការកែប្រែក្នុងទ្រង់ទ្រាយធំ ដែលធ្វើឡើងយ៉ាងតិច១ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័ននៃភាគី

(ឃ) « ការកែប្រែក្នុងទ្រង់ទ្រាយធំ » សំដៅដល់ការកែប្រែប្រភពដែលពាក់ព័ន្ធបង្កឱ្យមានការកើនឡើងនូវការសាយភាយដោយមិនរាប់បញ្ចូលនូវការផ្លាស់ប្តូរណាមួយនៅក្នុងការសាយភាយដែលបង្កមកពីការទាញយកមកវិញពីផលិតផលបន្ទាប់បន្សំ។ ភាគី អាចធ្វើការសម្រេចថាតើការកែប្រែមានលក្ខណៈទ្រង់ទ្រាយធំឬក៏មិនមាន

(ង) « ប្រភពមានស្រាប់ » សំដៅដល់ប្រភពដែលពាក់ព័ន្ធដែលមិនមែនជាប្រភពថ្មី

(ច) « កម្រិតកំណត់នៃការសាយភាយ » សំដៅដល់កម្រិតកំណត់កំហាប់ ម៉ាស ឬអត្រាសាយភាយនៃបារតឬសមាសធាតុបារត ដែលសំដៅដល់ « បារតសរុប » សាយភាយពីប្រភពអចល័ត។

៣- ភាគីនីមួយៗ ត្រូវកំណត់នូវក្រុមប្រភពអចល័តដែលពាក់ព័ន្ធមិនឱ្យយឺតជាងរយៈពេល៣ឆ្នាំក្រោយកាលបរិច្ឆេទនៃការផ្តល់សច្ចាប័ននិងផ្អែកលើមូលដ្ឋានទៀងទាត់។

៤- ភាគីមានប្រភពដែលពាក់ព័ន្ធ ត្រូវចាត់វិធានការត្រួតពិនិត្យការសាយភាយនិងរៀបចំផែនការជាតិដែលដាក់ចេញនូវវិធានការត្រួតពិនិត្យការសាយភាយ ព្រមទាំងកំណត់ទិសដៅ គោលដៅ និងលទ្ធផលរំពឹងទុកនៃការកាត់បន្ថយការសាយភាយបារត។ ផែនការជាតិ ត្រូវដាក់ជូនទៅសន្និសីទភាគីនៅក្នុងរយៈពេល៤ឆ្នាំក្រោយកាលបរិច្ឆេទចូលជាធរមាននៃការផ្តល់សច្ចាប័នរបស់ភាគី។ ប្រសិនបើភាគីមួយរៀបចំផែនការ

អនុវត្តដោយយោងតាមមាត្រា២០ ភាគីនោះអាចរាប់បញ្ចូលទៅក្នុងផែនការដែលបានរៀបចំដោយអនុលោមតាមវាក្យខណ្ឌនេះ។

៥- វិធានការទាំងឡាយ ត្រូវរាប់បញ្ចូលមួយឬច្រើនដូចតទៅតាមតែអាចធ្វើបាន៖

(ក) កម្រិតកំណត់នៃការសាយភាយសម្រាប់ត្រួតពិនិត្យនិងកាត់បន្ថយការសាយភាយពីប្រភពដែលពាក់ព័ន្ធ

(ខ) ការប្រើប្រាស់បច្ចេកទេសដ៏ប្រសើរដែលអាចរកបាននិងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ ដើម្បីត្រួតពិនិត្យការសាយភាយពីប្រភពដែលពាក់ព័ន្ធ

(គ) យុទ្ធសាស្ត្រត្រួតពិនិត្យសារធាតុបំពុលចម្រុះដែលអាចផ្តល់នូវអត្ថប្រយោជន៍រួមសម្រាប់ត្រួតពិនិត្យការសាយភាយបារត

(ឃ) វិធានការជំនួសដើម្បីកាត់បន្ថយការសាយភាយពីប្រភពដែលពាក់ព័ន្ធ។

៦- ភាគីនីមួយៗ ត្រូវរៀបចំនិងរក្សាទុករបាយការណ៍សារពើភណ្ឌស្តីពីការសាយភាយបារតពីប្រភពដែលពាក់ព័ន្ធតាមពេលដែលអាចធ្វើបាន និងមិនឱ្យលើសពីរយៈពេល៥ឆ្នាំក្រោយកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នអនុសញ្ញានេះ។

៧- នៅក្នុងកិច្ចប្រជុំលើកទី១ សន្និសីទភាគីត្រូវអនុម័តគោលការណ៍ស្តីពី៖

(ក) បច្ចេកទេសដ៏ល្អប្រសើរដែលអាចរកបាននិងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរដោយគិតគូរទៅលើភាពខុសគ្នារវាងប្រភពថ្មីនិងប្រភពដែលមានស្រាប់ ព្រមទាំងតម្រូវការដើម្បីកាត់បន្ថយឱ្យដល់អប្បបរមានៃទំហំផលប៉ះពាល់ទៅស្ថានប្រព័ន្ធបរិស្ថាន (ទឹក ដី ខ្យល់) និង

(ខ) វិធីសាស្ត្រសម្រាប់រៀបចំរបាយការណ៍សារពើភណ្ឌនៃការសាយភាយបារត។

៨- ភាគីនីមួយៗ ត្រូវដាក់បញ្ចូលព័ត៌មាននៃការអនុវត្តមាត្រានេះទៅក្នុងរបាយការណ៍ដែលត្រូវផ្តល់ជូនលេខាធិការដ្ឋាន ដូចមានចែងក្នុងមាត្រា២១ ជាពិសេសព័ត៌មានដែលទាក់ទងទៅនឹងវិធានការដែលភាគីបានអនុវត្តដោយអនុលោមតាមវាក្យខណ្ឌ៣ដល់៦ និងប្រសិទ្ធភាពនៃវិធានការទាំងនោះ។

## មាត្រា១០

## ការស្តុកទុកបណ្តោះអាសន្នបារតនិងសំណល់បារតផ្សេងទៀត ប្រកបដោយសុវត្ថិភាពបរិស្ថាន

១- មាត្រានេះ ត្រូវអនុវត្តចំពោះការស្តុកទុកបណ្តោះអាសន្នបារតនិងសមាសធាតុបារតដូចបានកំណត់ក្នុងមាត្រា៣ដែលមិនស្ថិតនៅក្នុងនិយមន័យសំណល់បារតដូចមានចែងក្នុងមាត្រា១១។

២- ភាគីនីមួយៗ ត្រូវចាត់វិធានការដើម្បីធានាថាការស្តុកទុកបណ្តោះអាសន្ននៃបារតនិងសមាសធាតុបារតដែលត្រូវបានអនុញ្ញាតប្រើប្រាស់ដោយភាគីនៃអនុសញ្ញានេះ ត្រូវអនុវត្តប្រកបដោយសុវត្ថិភាពបរិស្ថានដោយគិតគូរលើគោលការណ៍ណែនាំនានា និងដោយអនុលោមតាមតម្រូវការនានាដែលបានអនុម័តដូចមានចែងក្នុងវាក្យខណ្ឌ៣។

៣- សន្និសីទភាគី ត្រូវអនុម័តគោលការណែនាំស្តីពីការស្តុកទុកបណ្តោះអាសន្នបារតនិងសមាសធាតុបារត ប្រកបដោយសុវត្ថិភាពបរិស្ថានដោយគិតគូរទៅលើគោលការណ៍ណែនាំពាក់ព័ន្ធផ្សេងៗដែលបានរៀបចំឡើងក្រោមអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូននិងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែននិងគោលការណ៍ណែនាំពាក់ព័ន្ធផ្សេងទៀត។ សន្និសីទភាគី អាចអនុម័តឧបសម្ព័ន្ធក្នុងអនុសញ្ញានេះសម្រាប់តម្រូវការនានាសម្រាប់ការស្តុកទុកបណ្តោះអាសន្នដោយអនុលោមតាមមាត្រា៧។

៤- ភាគីនីមួយៗ ត្រូវសហការជាមួយភាគីផ្សេងទៀតនិងជាមួយអង្គការអន្តររដ្ឋាភិបាលនិងស្ថាប័នដទៃទៀតតាមតែអាចធ្វើទៅបាន ដើម្បីលើកកម្ពស់សមត្ថភាពសម្រាប់ការស្តុកទុកបណ្តោះអាសន្នបារតនិងសមាសធាតុបារតប្រកបដោយសុវត្ថិភាពបរិស្ថាន។

## មាត្រា១១
## សំណល់បារត

១- និយមន័យដែលពាក់ព័ន្ធផ្សេងៗនៃអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ត្រូវអនុវត្តចំពោះសំណល់ដែលស្ថិតនៅក្រោមអនុសញ្ញានេះសម្រាប់ភាគីនៃអនុសញ្ញាបាសែល។ ភាគីទាំងអស់នៃអនុសញ្ញានេះដែលមិនមែនជាភាគីអនុសញ្ញាបាសែលត្រូវប្រើប្រាស់និយមន័យតាមគោលការណ៍ដែលអនុវត្តចំពោះសំណល់ដែលស្ថិតក្រោមអនុសញ្ញានេះ។

២- សម្រាប់គោលបំណងនៃអនុសញ្ញានេះ សំណល់បារតមានន័យថាសារធាតុឬវត្ថុ៖

(ក) ដែលមានបារតឬសមាសធាតុបារត

(ខ) ដែលមានផ្ទុកបារតឬសមាសធាតុបារត ឬ

(គ) ដែលមានប្រឡាក់បារតឬសមាសធាតុបារត

ដោយសហការប្រកបដោយភាពចុះសម្រុងជាមួយគណៈកម្មការពាក់ព័ន្ធនានានៃអនុសញ្ញាបាសែល សន្និសីទភាគី ត្រូវកំណត់កម្រិតបរិមាណសំណល់បារតពាក់ព័ន្ធខាងលើដែលត្រូវបោះចោល ឬមានបំណងបោះចោល ឬដែលតម្រូវឱ្យបោះចោលដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ជាតិឬអនុសញ្ញានេះ។ និយមន័យនេះ គឺមិនរាប់បញ្ចូលសំណល់ស្រទាប់ដីឬថ្មលើស្រទាប់រុករករ៉ែ សំណល់ថ្ម និងកម្ទេចកម្ទីចេញពីអាជីវកម្មរ៉ែ លុះត្រាតែសំណល់ទាំងនោះមានផ្ទុកបារតឬសមាសធាតុបារតលើសពីកម្រិតកំណត់ដែលបានកំណត់ដោយសន្និសីទភាគី លើកលែងតែការធ្វើអាជីវកម្មបារតចម្បង។

៣- ភាគីនីមួយៗ ត្រូវចាត់វិធានការឱ្យបានសមស្របចំពោះសំណល់បារតគឺ៖

(ក) ត្រូវគ្រប់គ្រងប្រកបដោយសុវត្ថិភាពបរិស្ថាន ដោយគិតគូរលើគោលការណ៍ណែនាំដែលបានរៀបចំឡើងក្រោមអនុសញ្ញាបាសែលនិងអនុលោមតាមតម្រូវការដែលអនុម័តឧបសម្ព័ន្ធបន្ថែមដោយសន្និសីទភាគីយោងតាមមាត្រា២៧។ ក្នុងការរៀបចំលក្ខខណ្ឌ សន្និសីទភាគីត្រូវគិតគូរដល់កម្មវិធីនិងបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ភាគីទាំងអស់ស្តីពីការគ្រប់គ្រងសំណល់។



Media from www.moj.gov.kh resource from www.ocm.gov.kh

(ខ) មានតែសំណល់បារតដែលទាញយកមកប្រើប្រាស់ កែច្នៃឡើងវិញ ដកយកមកប្រើប្រាស់ឡើងវិញ ឬប្រើប្រាស់ឡើងវិញដោយផ្ទាល់ដែលអនុញ្ញាតដល់ភាគីស្ថិតក្រោមអនុសញ្ញានេះ ឬសម្រាប់ការបោះចោលប្រកបដោយសុវត្ថិភាពបរិស្ថានដែលអនុលោមតាមវាក្យខណ្ឌ៣(ក)

(គ) សម្រាប់ភាគីនៃអនុសញ្ញាបាសែលមិនត្រូវដឹកជញ្ជូនសំណល់ឆ្លងដែនអន្តរជាតិ លើកលែងតែក្នុងគោលបំណងបោះចោលប្រកបដោយសុវត្ថិភាពបរិស្ថានដោយអនុលោមជាមួយនឹងមាត្រានេះនិងអនុសញ្ញាបាសែល។ ក្នុងករណីអនុសញ្ញាបាសែលមិនបានអនុវត្តចំពោះការដឹកជញ្ជូនឆ្លងដែនអន្តរជាតិ ភាគីត្រូវអនុញ្ញាតចំពោះការដឹកជញ្ជូនឆ្លងដែនអន្តរជាតិបាន លុះត្រាតែបានគិតគូរដល់វិធានអន្តរជាតិស្តង់ដានិងគោលការណ៍ណែនាំពាក់ព័ន្ធ។

៤– សន្និសីទភាគី ត្រូវស្វែងរកកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធជាមួយគណៈកម្មការពាក់ព័ន្ធនៃអនុសញ្ញាបាសែល ក្នុងការត្រួតពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពលើគោលការណ៍ណែនាំដែលអនុលោមតាមវាក្យខណ្ឌ៣(ក) តាមតែអាចធ្វើបាន។

៥– ភាគីទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យសហការជាមួយភាគីផ្សេងទៀត និងអង្គការអន្តររដ្ឋាភិបាលនិងស្ថាប័នដទៃទៀតតាមតែអាចធ្វើបាន ដើម្បីអភិវឌ្ឍនិងពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលសម្រាប់ការគ្រប់គ្រងសំណល់បារតប្រកបដោយសុវត្ថិភាពបរិស្ថាន។

## មាត្រា១២
## ទីតាំងដែលទទួលរងការបំពុល

១– ភាគីនីមួយៗ ត្រូវខិតខំប្រឹងប្រែងដើម្បីរៀបចំផែនការយុទ្ធសាស្ត្រសមស្រប សម្រាប់ការកំណត់និងវាយតម្លៃទីតាំងដែលទទួលរងការបំពុលដោយបារតឬសមាសធាតុបារត។

២– សកម្មភាពទាំងឡាយណាសំដៅដល់ការកាត់បន្ថយហានិភ័យដែលបង្កពីទីតាំងទាំងនេះ ត្រូវអនុវត្តប្រកបដោយសុវត្ថិភាពបរិស្ថាននៅកន្លែងដែលអាចធ្វើទៅបាន ដោយបញ្ចូលការវាយតម្លៃហានិភ័យដល់សុខភាពមនុស្សនិងបរិស្ថានដែលបង្កពីទីតាំងទទួលរងការបំពុលដោយបារតឬសមាសធាតុបារត។

៣– សន្និសីទភាគី ត្រូវអនុម័តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងទីតាំងដែលទទួលរងការបំពុលដោយមានដាក់បញ្ចូលវិធីសាស្ត្រនិងវិធានសម្រាប់៖

(ក) ការធ្វើអត្តសញ្ញាណកម្មនិងកំណត់លក្ខណៈទីតាំងដែលទទួលរងការបំពុល

(ខ) ការចូលរួមពីសាធារណជន

(គ) ការវាយតម្លៃហានិភ័យដល់សុខភាពមនុស្សនិងបរិស្ថាន

(ឃ) ជម្រើសសម្រាប់គ្រប់គ្រងហានិភ័យបង្កឡើងដោយទីតាំងដែលទទួលរងការបំពុល

(ង) ការវាយតម្លៃពីគុណប្រយោជន៍និងគុណវិបត្តិ និង

(ច) ការផ្តល់សុពលភាពលទ្ធផល។

៤- ភាគីទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យសហការក្នុងការរៀបចំយុទ្ធសាស្ត្រនិងការអនុវត្តសកម្មភាពនានាសម្រាប់ការធ្វើអត្តសញ្ញាណ ការវាយតម្លៃ ការកំណត់អាទិភាព ការគ្រប់គ្រង និងការសម្អាតទីតាំងទទួលរងការបំពុលតាមតែអាចធ្វើបាន។

## មាត្រា១៣
## ធនធាននិងយន្តការហិរញ្ញវត្ថុ

១- ភាគីនីមួយៗ ត្រូវផ្តល់ធនធានតាមលទ្ធភាពដល់ការអនុវត្តសកម្មភាពថ្នាក់ជាតិដែលចូលរួមចំណែកដល់ការអនុវត្តអនុសញ្ញានេះដោយយោងតាមគោលនយោបាយ អាទិភាព ផែនការ និងកម្មវិធីជាតិ។ ធនធានទាំងនេះរួមមានការផ្តល់ថវិកាជាតិតាមរយៈគោលនយោបាយពាក់ព័ន្ធ ការរៀបចំយុទ្ធសាស្ត្រនិងថវិកាជាតិ និងការផ្តល់ថវិកាទ្វេភាគីនិងពហុភាគី ព្រមទាំងការចូលរួមពីវិស័យឯកជន។

២- ប្រសិទ្ធភាពនៃការអនុវត្តអនុសញ្ញានេះដោយភាគីជាប្រទេសកំពុងអភិវឌ្ឍ ត្រូវភ្ជាប់មកជាមួយនឹងប្រសិទ្ធភាពនៃការអនុវត្តមាត្រានេះ។

៣- ប្រភពជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសពហុភាគី តំបន់ និងទ្វេភាគី ព្រមទាំងការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យា ត្រូវបានលើកទឹកចិត្តដល់ការលើកកម្ពស់និងបង្កើនសកម្មភាពគ្រប់គ្រងបារតសំដៅគាំទ្រដល់ភាគីជាប្រទេសកំពុងអភិវឌ្ឍក្នុងការអនុវត្តអនុសញ្ញា ដែលទាក់ទងទៅនឹងធនធានហិរញ្ញវត្ថុ ជំនួយបច្ចេកទេសនិងការផ្ទេរបច្ចេកវិទ្យា។

៤- ភាគីនីមួយៗ ចំពោះសកម្មភាពដែលស្នើសុំថវិកាត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយដល់តម្រូវការជាក់ស្តែងនិងស្ថានភាពចាំបាច់របស់ភាគីជារដ្ឋដែនកោះតូចៗដែលកំពុងអភិវឌ្ឍនិងប្រទេសដែលមានការអភិវឌ្ឍតិចតួច។

៥- ត្រូវកំណត់យន្តការសម្រាប់ការផ្តល់ធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា។ យន្តការនេះគឺដើម្បីគាំទ្រដល់ភាគីជាប្រទេសកំពុងអភិវឌ្ឍ និងភាគីស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាលក្នុងការអនុវត្តកាតព្វកិច្ចក្រោមអនុសញ្ញានេះ។

៦- យន្តការនេះត្រូវដាក់បញ្ចូលៈ

(ក) មូលនិធិបរិស្ថានសកល និង

(ខ) កម្មវិធីអន្តរជាតិជាក់លាក់សម្រាប់គាំទ្រដល់ការកសាងសមត្ថភាពនិងជំនួយបច្ចេកទេស។

៧- មូលនិធិបរិស្ថានសកល ត្រូវផ្តល់ធនធានថវិកាថ្មីៗ គ្រប់គ្រាន់ អាចព្យាករបាន និងទាន់ពេលវេលាសម្រាប់ឆ្លើយតបទៅនឹងការចំណាយក្នុងការគាំទ្រដល់ការអនុវត្តអនុសញ្ញានេះដូចបានព្រមព្រៀងដោយសន្និសីទភាគី។ សម្រាប់គោលបំណងនៃអនុសញ្ញានេះ មូលនិធិបរិស្ថានសកលត្រូវប្រតិបត្តិតាមគោលការណ៍និងប្រកបដោយគណនេយ្យភាពចំពោះសន្និសីទភាគី។ សន្និសីទភាគី ត្រូវផ្តល់នូវគោលការណ៍ស្តីពីយុទ្ធសាស្ត្រ គោលនយោបាយ កម្មវិធីអាទិភាព និងសិទ្ធិសម្រាប់ការទទួលបាននិងការប្រើប្រាស់ប្រភពហិរញ្ញវត្ថុ។ បន្ថែមពីនេះទៀត សន្និសីទភាគីត្រូវផ្តល់ការណែនាំពីបញ្ជីសូចនាករនៃប្រភេទសកម្មភាពដែលអាចទទួល

បានការគាំទ្រហិរញ្ញវត្ថុពីមូលនិធិបរិស្ថានសកល។ មូលនិធិបរិស្ថានសកល ត្រូវផ្តល់នូវធនធានដើម្បីឆ្លើយតបទៅនឹងកំណើននៃចំណាយលើបរិស្ថានពិភពលោកនិងចំណាយទាំងស្រុងចំពោះសកម្មភាពជំរុញដែលបានព្រមព្រៀង។

៨- ក្នុងការផ្តល់ធនធានសម្រាប់សកម្មភាព មូលនិធិបរិស្ថានសកលត្រូវគិតគូរដល់ការចំណាយលើសកម្មភាពកាត់បន្ថយបារតដែលបានស្នើឡើង។

៩- សម្រាប់គោលបំណងនៃអនុសញ្ញានេះ កម្មវិធីដែលបានកំណត់ក្នុងវាក្យខណ្ឌ៦(ខ) ត្រូវអនុវត្តតាមគោលការណ៍ណែនាំនិងប្រកបដោយគណនេយ្យភាពដល់សន្និសីទភាគី។ សន្និសីទភាគីនៅកិច្ចប្រជុំលើកទី១ ត្រូវកំណត់ស្ថាប័នដែលមានស្រាប់ ទទួលបន្ទុកសម្រាប់កម្មវិធីអន្តរជាតិជាក់លាក់សម្រាប់គាំទ្រដល់ការកសាងសមត្ថភាពនិងជំនួយបច្ចេកទេស ហើយផ្តល់ការណែនាំនិងរយៈពេលនៃកម្មវិធីនេះ។ ភាគីនិងភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានអញ្ជើញឱ្យចូលរួមផ្តល់ធនធានហិរញ្ញវត្ថុដល់កម្មវិធីនេះដោយផ្អែកតាមការស្ម័គ្រចិត្ត។

១០- សន្និសីទភាគីនិងអង្គភាពនានាដែលមានយន្តការ នៅឯកិច្ចប្រជុំសន្និសីទភាគីលើកទី១ត្រូវយល់ព្រមលើការរៀបចំដល់សុពលភាពចំពោះវាក្យខណ្ឌខាងលើ។

១១- សន្និសីទភាគីមិនឱ្យយឺតពីកិច្ចប្រជុំលើកទីបី ត្រូវធ្វើការត្រួតពិនិត្យឡើងវិញផ្អែកលើមូលដ្ឋានទៀងទាត់នូវកម្រិតធនធានហិរញ្ញវត្ថុ ត្រួតពិនិត្យឡើងវិញគោលការណ៍ដែលផ្តល់ដោយសន្និសីទភាគីដល់អង្គភាពពាក់ព័ន្ធសម្រាប់ការប្រតិបត្តិយន្តការដែលបានបង្កើតឡើងក្រោមមាត្រានេះ និងប្រសិទ្ធភាពនិងលទ្ធភាពឆ្លើយតបទៅនឹងការប្រែប្រួលតម្រូវការរបស់ភាគីជាប្រទេសកំពុងអភិវឌ្ឍនិងភាគីស្ថិតក្រោមសេដ្ឋកិច្ចអន្តរកាល។ ដោយផ្អែកលើការពិនិត្យឡើងវិញនេះ សន្និសីទភាគីត្រូវចាត់វិធានការសមស្របដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃយន្តការនេះ។

១២- ភាគីទាំងអស់ ត្រូវបានអញ្ជើញឱ្យចូលរួមចំណែកក្នុងការអនុវត្តយន្តការនេះទៅតាមលទ្ធភាព។ យន្តការនេះ ត្រូវជំរុញដល់ការផ្តល់ធនធានពីប្រភពផ្សេងៗ រួមមានវិស័យឯកជន ហើយត្រូវស្វែងរកការបង្កើននូវធនធានសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាព។

## មាត្រា១៤
## ការកសាងសមត្ថភាព ការផ្តល់ជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យា

១- ភាគីទាំងអស់ ត្រូវសហការផ្តល់ការកសាងសមត្ថភាពនិងជំនួយបច្ចេកទេសឱ្យបានទាន់ពេលវេលា និងសមស្របដល់ភាគីជាប្រទេសមានការអភិវឌ្ឍតិចឬរដ្ឋដែនកោះតូចៗដែលកំពុងអភិវឌ្ឍ និងភាគីជាប្រទេសដែលស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល ដើម្បីជួយក្នុងការអនុវត្តកាតព្វកិច្ចស្ថិតក្រោមអនុសញ្ញានេះ។

២- ការកសាងសមត្ថភាពនិងការផ្តល់ជំនួយបច្ចេកទេសដោយអនុលោមតាមវាក្យខណ្ឌ១ និងមាត្រា១៣ អាចត្រូវផ្តល់តាមរយៈការរៀបចំថ្នាក់តំបន់ អនុតំបន់ និងថ្នាក់ជាតិ រួមមានមជ្ឈមណ្ឌលថ្នាក់តំបន់និងអនុតំបន់ដែលមានស្រាប់តាមរយៈកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី និងតាមរយៈភាពជាដៃគូរួមមាន វិស័យ

ឯកជន។ កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលកិច្ចព្រមព្រៀងវិស័យបរិស្ថានពហុភាគីនៅក្នុងផ្នែកសារជាតុគីមីនិងសំណល់ គួរត្រូវបង្កើនប្រសិទ្ធភាពនៃការផ្តល់ជំនួយបច្ចេកទេស។

៣- ភាគីប្រទេសអភិវឌ្ឍនិងភាគីផ្សេងទៀតតាមលទ្ធភាពរបស់ខ្លួន ដោយមានការគាំទ្រពីវិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងៗទៀតតាមដែលអាចធ្វើទៅបានត្រូវជំរុញនិងសម្របសម្រួលក្នុងការអភិវឌ្ឍ ការផ្ទេរ ការផ្សព្វផ្សាយ និងការទទួលបានបច្ចេកវិទ្យាជំនួសទំនើបប្រកបដោយសុវត្ថិភាពបរិស្ថានទៅដល់ភាគីប្រទេសកំពុងអភិវឌ្ឍ ជាពិសេសភាគីប្រទេសអភិវឌ្ឍតិចតួចបំផុតឬរដ្ឋដែនកោះតូចៗដែលកំពុងអភិវឌ្ឍនិងភាគីប្រទេសស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល ដើម្បីពង្រឹងសមត្ថភាពក្នុងការអនុវត្តអនុសញ្ញានេះប្រកបដោយប្រសិទ្ធភាព។

៤- សន្និសីទភាគីនៅកិច្ចប្រជុំលើកទី២ ដោយផ្អែកលើមូលដ្ឋានទៀងទាត់ដែលត្រូវគិតពិចារណាលើការដាក់ឱ្យពិនិត្យនិងការរាយការណ៍ពីភាគីនីមួយៗរួមមាន ព័ត៌មានទាំងឡាយដូចដែលមានចែងក្នុងមាត្រា២១ និងព័ត៌មានដែលបានផ្តល់ដោយភាគីពាក់ព័ន្ធផ្សេងៗទៀត ត្រូវ៖

(ក) ពិចារណាព័ត៌មានស្តីពីគំនិតផ្តួចផ្តើមដែលមានស្រាប់និងវឌ្ឍនភាពនៃការអនុវត្តបច្ចេកវិទ្យាជំនួស

(ខ) ពិចារណាសេចក្តីត្រូវការរបស់ភាគីសម្រាប់បច្ចេកវិទ្យាជំនួស ជាពិសេសភាគីប្រទេសកំពុងអភិវឌ្ឍ និង

(គ) កំណត់បញ្ហាប្រឈមដែលភាគីបានជួបប្រទះក្នុងការផ្ទេរបច្ចេកវិទ្យាជាពិសេសភាគីប្រទេសកំពុងអភិវឌ្ឍ។

៥- សន្និសីទភាគី ត្រូវផ្តល់អនុសាសន៍លើការលើកកម្ពស់ដល់ការកសាងសមត្ថភាព ការផ្តល់ជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យាឱ្យកាន់តែប្រសើរថែមទៀតដូចដែលមានចែងក្នុងមាត្រានេះ។

## មាត្រា១៥
## គណៈកម្មាធិការប្រតិបត្តិនិងត្រួតពិនិត្យ

១- យន្តការនេះរួមមាន គណៈកម្មាធិការដែលជាអង្គភាពជំនួយដល់សន្និសីទភាគី ត្រូវបានបង្កើតឡើងដើម្បីជំរុញការអនុវត្ត ការត្រួតពិនិត្យ ការប្រតិបត្តិតាមរាល់បទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុសញ្ញានេះ។ យន្តការនេះរួមមាន គណៈកម្មាធិការត្រូវធ្វើការសម្របសម្រួលនិងត្រូវពិនិត្យ ជាពិសេសលើលទ្ធភាពនិងស្ថានភាពផ្សេងៗនៃភាគី។

២- គណៈកម្មាធិការ ត្រូវជំរុញការអនុវត្តនិងត្រួតពិនិត្យការប្រតិបត្តិតាមរាល់បទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុសញ្ញានេះ។ គណៈកម្មាធិការ ត្រូវត្រួតពិនិត្យលើទាំងបញ្ហាជាបុគ្គលនិងជាប្រព័ន្ធនៃការអនុវត្តនិងការប្រតិបត្តិ ព្រមទាំងការផ្តល់អនុសាសន៍តាមដែលអាចធ្វើបានដល់សន្និសីទភាគី។

៣- គណៈកម្មាធិការនេះ ត្រូវមានសមាជិកចំនួន១៥រូបដែលតែងតាំងដោយភាគីនិងដោយការបោះឆ្នោតជ្រើសរើសពីសន្និសីទភាគី ដោយគិតពិចារណាប្រកបដោយសមភាពចំពោះការជ្រើសរើសតំណាងតាមតំបន់ភូមិសាស្ត្រផ្អែកលើតំបន់ទាំង៥នៃអង្គការសហប្រជាជាតិ។ សមាជិកដំបូង ត្រូវបានបោះឆ្នោតជ្រើសរើស

នៅក្នុងកិច្ចប្រជុំលើកទី១នៃសន្និសីទភាគី អនុលោមតាមវិធាននៃនីតិវិធីដែលបានអនុម័តដោយសន្និសីទភាគីដូចមានចែងក្នុងវាក្យខណ្ឌ៥។ សមាជិកគណៈកម្មាធិការ មានសមត្ថកិច្ចនៅក្នុងវិស័យពាក់ព័ន្ធនឹងអនុសញ្ញានេះនិងមានជំនាញសមស្រប។

៤- គណៈកម្មាធិការ អាចពិចារណាលើបញ្ហានានាដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

(ក) ការដាក់ឱ្យត្រួតពិនិត្យជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងការប្រតិបត្តិតាមរបស់ភាគីនីមួយៗ

(ខ) របាយការណ៍ថ្នាក់ជាតិដោយយោងតាមមាត្រា២១ និង

(គ) សំណើនានាពីសន្និសីទភាគី។

៥- គណៈកម្មាធិការ ត្រូវផ្តល់ការពន្យល់រៀបរាប់អំពីវិធាននៃនីតិវិធីដែលស្ថិតនៅក្រោមការអនុម័តដោយកិច្ចប្រជុំលើកទី២នៃសន្និសីទភាគី។ សន្និសីទភាគី អាចអនុម័តបន្ថែមនូវលក្ខខណ្ឌការងារសម្រាប់គណៈកម្មាធិការនេះ។

៦- គណៈកម្មាធិការ ត្រូវធ្វើការអនុម័តលើអនុសាសន៍នានាដោយផ្អែកលើមូលដ្ឋានគាំទ្រជាឯកច្ឆន្ទ។ ប្រសិនបើគណៈកម្មាធិការ បានស្វែងរកការគាំទ្រជាឯកច្ឆន្ទអស់លទ្ធភាពនិងមិនអាចឈានដល់ការសម្រេចជាឯកច្ឆន្ទផ្អែកតាមកូរ៉ុម២/៣នៃសមាជិក ដូច្នេះអនុសាសន៍ទាំងអស់នឹងត្រូវអនុម័តដោយការបោះឆ្នោតមតិភាគច្រើន៣/៤នៃសមាជិកដែលមានវត្តមាននិងបានបោះឆ្នោត។

## មាត្រា១៦
## ផ្នែកសុខភាព

១- ភាគីទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យ៖

(ក) ជំរុញការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រនិងកម្មវិធីនានាដើម្បីកំណត់អត្តសញ្ញាណនិងការពារប្រជាពលរដ្ឋពីហានិភ័យ ជាពិសេសប្រជាពលរដ្ឋដែលងាយរងគ្រោះដោយដាក់បញ្ចូលនូវការអនុម័តគោលការណ៍ណែនាំសុខភាពតាមបែបវិទ្យាសាស្ត្រដែលទាក់ទងទៅនឹងការទទួលរងផលប៉ះពាល់ពីបារតនិងសមាសធាតុបារត ដោយកំណត់គោលដៅសម្រាប់ការកាត់បន្ថយការទទួលរងផលប៉ះពាល់ពីបារតតាមដែលអាចធ្វើទៅបាននិងអប់រំដល់សាធារណៈដោយមានការចូលរួមពីវិស័យសុខភាពសាធារណៈនិងវិស័យពាក់ព័ន្ធផ្សេងៗទៀត។

